ក

មាតិកា

I-ខុទ្ទកាល័យព្រះមហាក្សត្រ

១-ព្រះរាជក្រម

០២-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០២៨ ស្តីពីការប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាង និងក្នុង រង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្របសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ៧៩៤៨

២-ព្រះរាជក្រឹត្យ

៣០-១១-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១១០៦/៤៦៨ ស្តីពីការតែងតាំង ឯកឧត្តម ចំនួន ០២ រូប ជាទីប្រឹក្សា និង ជាជំនួយការសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ៨០១៥

០៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៧៨ ស្តីពីការតែងតាំង លោក **ឡុច សៀ** ជា ឧកញ៉ា ៨០១៦

០៧-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨០ ស្តីពីការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស សុវត្ថារា តាមលំដាប់ថ្នាក់ ចំពោះឯកឧត្តម ចំនួន ០២ រូប ៨០១៧

០៩-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨១ ត្រូវបានអនុញ្ញាតជូនចៅក្រម **សៅ មៀច** បន្តបម្រើការងារជាចៅក្រមនៅតុលាការក្រុងភ្នំពេញមួយរយៈពេលទៀត ៨០១៨

០៩-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៤៨២ ស្តីពីការប្រោសព្រះរាជទាន ចំពោះឯកឧត្តម **សៀង ណារ៉ា** នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ៨០១៩

II-ក្រុមប្រឹក្សាធម្មនុញ្ញ

១២-១២-២០០៦ -សេចក្តីសម្រេចលេខ ០៨៨/០១៥/២០០៦ កបធ.ច ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦ ៨០២០

III-រាជរដ្ឋាភិបាល

អនុក្រឹត្យ

១២-១២-២០០៦ -អនុក្រឹត្យលេខ ១៤២ អនក្រ.បក ស្តីពីការកែសម្រួលមាត្រា១៦ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ៨០២២

១២-១២-២០០៦ -អនុក្រឹត្យលេខ ១៤៣ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨០២៥

១២-១២-២០០៦ -អនុក្រឹត្យលេខ ១៤៤ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៨០២៧

០៨-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៣ អនក្រ.តត ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៨០២៩

០៨-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៤ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨០៣០

០៨-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ ៨០៣១

០៨-១២-២០០៦ -អនុក្រឹត្យលេខ ៧៦៦ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៨០៣២

IV~ការងារបណ្តាក្រសួង

១~ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

០៧-១២-២០០៦ -សារាចរណែនាំលេខ ០១២សហវ ស្តីពីការរៀបចំផែនការលទ្ធកម្ម ៨០៣៣

២~ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

០១-១២-២០០៦ -ប្រកាសលេខ ១៩៦២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ថ្នាធ្នង់** " ស្ថិតនៅក្នុងឃុំ ថ្នាធ្នង់ ស្រុក រំដួល ខេត្ត ស្វាយរៀង ៨០៣៩

០១-១២-២០០៦ -ប្រកាសលេខ ១៩៦៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **អង្គតាសូរ** " ស្ថិតនៅក្នុងឃុំ អង្គតាសូរ ស្រុក ស្វាយជ្រំ ខេត្ត ស្វាយរៀង ៨០៤០

០១-១២-២០០៦ -ប្រកាសលេខ ១៩៦៤ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **អណ្តូងពោធិ៍** " ស្ថិតនៅក្នុងឃុំ អណ្តូងពោធិ៍ ស្រុក រមាសហែក ខេត្ត ស្វាយរៀង ៨០៤១

០១-១២-២០០៦ -ប្រកាសលេខ.១៩៦៥ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ស្វាយធន្ទឹម** " ស្ថិតនៅក្នុងឃុំ ត្រពាំងស្តៅ ស្រុក រមាសហែក ខេត្ត ស្វាយរៀង ៨០៤២

០១-១២-២០០៦ -ប្រកាសលេខ ១៩៦៦ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **សំបួរ** " ស្ថិតនៅក្នុងឃុំ សំបួរ ស្រុក ស្វាយទាប ខេត្ត ស្វាយរៀង ៨០៤៣

០១-១២-២០០៦ -ប្រកាសលេខ ១៩៦៧ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ស្វាយតឿ** " ស្ថិតនៅក្នុងឃុំ ស្វាយតឿ ស្រុក កំពង់រោទិ៍ ខេត្ត ស្វាយរៀង ៨០៤៤

០១-១២-២០០៦ -ប្រកាសលេខ ១៩៦៨ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ពពែត** " ស្ថិតនៅក្នុងឃុំ ពពែត ស្រុក ស្វាយទាប ខេត្ត ស្វាយរៀង ៨០៤៥

០១-១២-២០០៦ -ប្រកាសលេខ ១៩៦៩ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "**ស្រែទាលខាងកើត**" ស្ថិតនៅក្នុងឃុំ ដងកាំបិត ស្រុក សណ្តាន់ ខេត្ត កំពង់ធំ ៨០៤៦

០១-១២-២០០៦ -ប្រកាសលេខ ១៩៧០ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **សង្កែ** " ស្ថិតនៅក្នុងឃុំ សង្កែ ស្រុក រំដួល ខេត្ត ស្វាយរៀង ៨០៤៧

០១-១២-២០០៦ -ប្រកាសលេខ ១៩៧១ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ហ៊ុន សែន មុខដា** " ស្ថិតនៅក្នុងឃុំ មុខដា ស្រុក រមាសហែក ខេត្ត ស្វាយរៀង ៨០៤៨

០១-១២-២០០៦ -ប្រកាសលេខ ១៩៧២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ "**ទួលអង្កែរណ្តូត**" ស្ថិតនៅក្នុងឃុំ ជ្រលង ស្រុក បារាយណ៍ ខេត្ត កំពង់ធំ ៨០៤៩

០១-១២-២០០៦ -ប្រកាសលេខ ១៩៧៣ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ " **ចំបក់** " ស្ថិតនៅក្នុងឃុំ ចំបក់ ស្រុក ស្វាយជ្រំ ខេត្ត ស្វាយរៀង ៨០៥០

៣_ឧិស្ថិ៍ការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៧៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឌី អេស ភី អ៊ីម & អិច ខូ អិលធីឌី** ៨០៥១

០៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៧៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទ៊ាទ៊ាស៊ី គ្លូប៊ល (ខេមបូឌា)** ៨០៥៣

០៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៧៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាទើក្រាហ្វ ហាយតិច (ខេមបូឌា)** ៨០៥៥

០៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៧៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច ជី ប៊ី គ្រេឌីង** ៨០៥៧

០៥-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៨២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ម៉ាស្ទ័រ ស៊ីបផ្លាយ អេន ស៊ើវីស** ៨០៥៩

០៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៨៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អឹម ប៊ី ធី អេស** ៨០៦១

០៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៨៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាយ អិន ៤ ខមភេនី** ៨០៦៣

០៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៩១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ស៊ិន ទៀន** ៨០៦៥

០៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៩៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ពន្លឺ ផ្កាយកូនមាន់** ៨០៦៧

០៦-៩-២០០៦ -លិខិតបញ្ជាក់លេខ ២២៩៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សំបូរណ្ណ ប្រូស្ពើរិធី** ៨០៦៩

ព្រះរាជក្រម

នស/រកម/១២០៦/០២៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និងពិធីសារទី១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាសាធារណរដ្ឋប្រជាមានិតចិន សាធា-

រណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញនិងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ១ ទី ២ ទី ៤ ទី ៧ ទី ៩ ទី ១១ ទី ១២ ទី ១៣អា ទី ១៣បេ ទី ១៥ ទី ១៦ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការសម្រួល ការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

មាត្រា ១.-

អនុម័តយល់ព្រមលើឧបសម្ព័ន្ធទី ២ ទី ៤ ទី ៧ ទី ១១ ទី ១២ ទី ១៣អា ទី ១៥ វិសោធនកម្មមាត្រា ១៧ និងពិធីសារទី ១ ដែលធ្វើនៅទីក្រុងភ្នំពេញ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ និងឧបសម្ព័ន្ធទី ១ ទី ៩ ទី ១៣បេ ទី ១៦ ដែលធ្វើនៅទីក្រុងវៀងច័ន្ទ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ សម្រាប់អនុវត្តកិច្ចព្រមព្រៀង រវាងនិងក្នុង រង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្ដីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តឧបសម្ព័ន្ធ ពិធីសារ និងវិសោធនកម្មនៃកិច្ចព្រមព្រៀងនេះ ។

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វបន្ទាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

ពរល.០៦១២.៥០១

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

ហត្ថលេខា

ស៊ុន ចាន់ថុល

លេខ : ៤៥០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃួន ឌីនភេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

ឧបសម្ព័ន្ធទី ១,២,៤,៧,៩, ១១,១២, ១៣អា ,១៣បេ,១៥ ,១៦
និងពិធីសារទី១

សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS

ស្តីពីការសំរួលការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋ ឆ្លងកាត់ព្រំដែន

នាយកដ្ឋានផែនការ

សីហា ឆ្នាំ ២០០៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និង ដឹកជញ្ជូន

លេខ:...1.8.5.៨...............ស.ក

រាជធានីភ្នំពេញ, ថ្ងៃទី 13 ខែ 9 ឆ្នាំ ២០០6

សូមគោរពជូន
សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

កម្មវត្ថុ: សំណើកែសំរួលអត្ថបទសេចក្តីព្រាងច្បាប់ និងសេចក្តីថ្លែងហេតុ ដើម្បីបញ្ជូន និងដាក់ស្នើសុំការផ្តល់សច្ចាប័នសាជាថ្មីពីសភាជាតិលើឧបសម្ព័ន្ធ *ទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និងពិធីសារទី១* នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

យោង: ស្មារតីនៃកិច្ចប្រជុំ ជាមួយគណៈកម្មាធិការទី ៥ នៃរដ្ឋសភាជាតិ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ ខ្ញុំមានកិត្តិយស សូមជំរាបជូន **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា : កាលពីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៦ កន្លងទៅ ក្រសួងសាធារណការ និង ដឹកជញ្ជូន បានជួបប្រជុំជាមួយគណៈកម្មការទី៥របស់រដ្ឋសភាជាតិ ដើម្បីពិនិត្យមើលសេចក្តីព្រាងច្បាប់*ស្តីពីការអនុម័តយល់ព្រមលើឧបសម្ព័ន្ធ ទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា១៧ និង ពិធីសារទី១ សម្រាប់អនុវត្តកិច្ចព្រមព្រៀងរវាង និង ក្នុងរង្វង់រដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និង សាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និង ពលរដ្ឋឆ្លងកាត់ព្រំដែន ។* ក្នុងឱកាសនោះ គណៈកម្មការទី៥នៃរដ្ឋសភាជាតិ បានស្នើឱ្យក្រសួងសាធារណការ និង ដឹកជញ្ជូន ដែលជាតំណាងរាជរដ្ឋាភិបាល ធ្វើការកែតម្រូវនូវសេចក្តីព្រាងអត្ថបទច្បាប់ និង សេចក្តីថ្លែងហេតុ នៅលើចំណុចដូចខាងក្រោម :

១~ ស្នើកែតម្រូវឈ្មោះប្រទេសពី : *សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ* អោយបានត្រឹមត្រូវទៅជា *សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ* ទាំងនៅលើសេចក្តីព្រាងច្បាប់ និង សេចក្តីថ្លែងហេតុ ។

២~ ស្នើសុំបន្ថែម និង បំពេញឈ្មោះប្រទេសទាំងអស់ នៃកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ ទៅក្នុងចំណងជើងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ ទាំងនៅលើសេចក្តីព្រាងច្បាប់ និងសេចក្តីថ្លែងហេតុ ។ ដោយហេតុថា :

- មាត្រា៤ នៃវិសោធនកម្ម នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ បានចែងថា : " មាត្រា ៣៦ស្ទួន ភារចូល: *កិច្ចព្រមព្រៀងបើកចំហ សំរាប់ការចូល ពីប្រទេសណាមួយនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ។ លិខិតុបករណ៍នៃការចូល ត្រូវតំកល់ទុកនៅរដ្ឋាភិបាលនៃភាគីចុះកិច្ចសន្យាទាំងឡាយ* " ។

កម្ពុជា សាធារណរដ្ឋប្រជាមានិតចិន និង សហភាពមីយ៉ាន់ម៉ា បានតំកល់ទុកលិខិតុបករណ៍នៃការចូលទៅភាគី ចុះកិច្ចសន្យាទាំងអស់ ជាបន្តបន្ទាប់គ្នារួចមកហើយ ។

- មាត្រា៩ នៃវិសោធនកម្ម នៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ បានចែងថា ៈ *" បន្ថែមពីលើការយល់ព្រមចូលពីប្រទេសណាមួយនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ ចំណងជើងនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌ នឹងត្រូវធ្វើវិសោធនកម្មដោយស្វ័យប្រវត្តិ ដើម្បីបញ្ចូលឈ្មោះប្រទេស ដែលបានយល់ព្រមចូល "* ។

ចំណងជើងពេញលេញនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌគឺ ៈ *កិច្ចព្រមព្រៀងរវាង និង ក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន* ។

ក្រសួងសាធារណការ និង ដឹកជញ្ជូនបានឯកភាព និងបានរៀបចំកែសំរួលខ្លឹមសារអត្ថបទសេចក្តីព្រាងច្បាប់ និង សេចក្តីថ្លែងហេតុ ស្របទៅតាមសំណើរបស់គណៈកម្មាធិការទី៥ នៃរដ្ឋសភាជាតិ ដើម្បីរៀបចំបញ្ជូន និងដាក់ស្នើសុំការផ្តល់សច្ចាប័នសាជាថ្មីពីសភាជាតិ ដូចមានឯកសារជូនភ្ជាប់មកជាមួយនេះ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ ខ្ញុំសូមគោរពស្នើសុំ **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យលទ្ធភាពកែសំរួលអត្ថបទច្បាប់ និង បញ្ជូនទៅរដ្ឋសភា ដើម្បីស្នើសុំការផ្តល់សច្ចាប័នសាជាថ្មី ពីសភាជាតិ *លើឧបសម្ព័ន្ធ ទី១ ទី២ ទី៤ ទី៧ ទី៩ ទី១១ ទី១២ ទី១៣អា ទី១៣បេ ទី១៥ ទី១៦ វិសោធនកម្មមាត្រា ១៧ និង ពិធីសារទី១* នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដោយអនុគ្រោះ ។

សូម **សម្តេចនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ

ស៊ុន-ចាន់ថុល

ចំលងជូន

- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលបន្ទុកសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ*
- *លេខាធិការដ្ឋានជាតិមហាអនុតំបន់ទន្លេមេគង្គ CDC*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ : ...1696...... សក.

រាជធានីភ្នំពេញ. ថ្ងៃទី ៨៤ ខែ ៩ ឆ្នាំ ២០០៦

សូមគោរពជូន

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កម្មវត្ថុ: សំណើបញ្ជូន និងដាក់ស្នើសុំសារជាថ្មី ការផ្តល់សច្ចាប័នពីសភាជាតិ លើឧបសម្ព័ន្ធទី២ ទី៤ ទី៧ ទី១១ ទី១២ ទី១៣អា ទី១៥ វិសោធនកម្មមាត្រាទី១៧ និងពិធីសារទី១ និងឧបសម្ព័ន្ធទី១ ទី៩ ទី១៣បេ និងទី១៦ នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ។

យោង: ស្មារតីនៃកិច្ចប្រជុំ ជាមួយគណៈកម្មាធិការទី ៥ នៃរដ្ឋសភាជាតិ កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៦ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបឯកឧត្តមថា ក្រសួងសាធារណការនិងដឹកជញ្ជូន បានរៀបចំកែសំរួលខ្លឹមសារ ឯកសារមួយចំនួន ទៅតាមសំណើរបស់គណៈកម្មាធិការទី៥ នៃរដ្ឋសភាជាតិ ដើម្បីរៀបចំ បញ្ជូន និងដាក់ស្នើសុំសារជាថ្មី ក្នុងការផ្តល់សច្ចាប័នពីសភាជាតិ លើឧបសម្ព័ន្ធទី២ ទី៤ ទី៧ ទី១១ ទី១២ ទី១៣អា ទី១៥ វិសោធនកម្ម មាត្រាទី១៧ និងពិធីសារទី១ និង ឧបសម្ព័ន្ធទី១ ទី៩ ទី១៣បេ និងទី១៦ នៃកិច្ចព្រមព្រៀង GMS ដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដូចមានឯកសារជូនភ្ជាប់មកជាមួយនេះ ។

អាស្រ័យហេតុដូចបានជំរាបជូនខាងលើ ខ្ញុំសូមឯកឧត្តមមេត្តាពិនិត្យលទ្ធភាព បញ្ជូន និងដាក់ស្នើសុំសារជាថ្មី ក្នុងការផ្តល់សច្ចាប័នពីសភាជាតិ លើឧបសម្ព័ន្ធទី២ ទី៤ ទី៧ ទី១១ ទី១២ ទី១៣អា ទី១៥ វិសោធនកម្មមាត្រាទី១៧ និង ពិធីសារទី១ និងឧបសម្ព័ន្ធទី១ ទី៩ ទី១៣បេ និងទី១៦នៃកិច្ចព្រមព្រៀងGMSដឹកជញ្ជូនឆ្លងកាត់ព្រំដែនដោយអនុគ្រោះ ។

សូមឯកឧត្តមទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

រដ្ឋមន្ត្រី

ស៊ុន ចាន់ថុល

ចំលងជូន
- ឯកឧត្តមអគ្គាធិការ និងជានាយកខុទ្ទកាល័យ
- ឯកសារ កាលប្បវត្តិ

552 19 APR 2004

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...២១០...សរ(ស.ក)..

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០០៤

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បកចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

ប្រគល់សិទ្ធិពេញសមត្ថភាពជូនឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាល លើឧបសម្ព័ន្ធ និងពិធីសារ សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែនដូចខាងក្រោមៈ

១-ឧបសម្ព័ន្ធទី៦ : ការចុះបញ្ជីយានយន្តទៅក្នុងចរាចរអន្តរជាតិ

២-ឧបសម្ព័ន្ធទី៤ : ការសំរបសំរួលបែបបទឆ្លងកាត់ព្រំដែន

៣-ឧបសម្ព័ន្ធទី៧ : បទប្បញ្ញត្តិចរាចរ និងផ្លាកសញ្ញាតាមផ្លូវថ្នល់

៤-ឧបសម្ព័ន្ធទី១១ : បទដ្ឋាន ឬមាត្រដ្ឋានស្តង់ដារ និងលក្ខណៈបច្ចេកទេស

៥-ឧបសម្ព័ន្ធទី១២ : សេវា និងសម្បទា ឬ មធ្យោបាយសំរាប់ការឆ្លងកាត់ និង ការឆ្លងកាត់ព្រំដែន

៦-ឧបសម្ព័ន្ធទី១៣ អា : របបគ្រប់គ្រងទទួលខុសត្រូវ អ្នកដឹកជញ្ជូនពហុរូបភាព

៧-ឧបសម្ព័ន្ធទី១៥ : ប្រពន្ធ័ចាត់ថ្នាក់ទំនិញ

៨-ពិធីសារទី១ : ការកំណត់ផ្លូវ និងផ្លូវរបៀង ព្រមទាំងចំនុចចេញ-ចូលឆ្លងកាត់ព្រំដែន

៩-វិសោធនកម្មមាត្រាទី១៧ កិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ស្តីពីការទទួលស្គាល់បណ្ណ័បើកបរទៅវិញទៅមកដែលចេញអោយដោយបណ្តាប្រទេសក្នុងមហាអនុតំបន់ទន្លេមេគង្គ

ក្នុងឱកាសនៃកិច្ចប្រជុំលើកដំបូង គណៈកម្មការរួមតំបន់ GMS សំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងកិច្ចប្រជុំពាក់ពន្ធ័ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ២៧-៣០ ខែមេសា ឆ្នាំ២០០៤ នៅរាជធានីភ្នំពេញខាងមុខនេះ ។

ដើម្បីជាសក្ខីភាពនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើសិទ្ធិប្រទាននេះ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

552
19 APR 2004

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

No: 20 D.F.P

Phnom Penh, APRIL 19 *2004*

DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia.
- Having seen the Royal Decree NS/RTK/1198/72 of November 30, 1998 on the Formation of the Royal Government of Cambodia.
- Having seen the Royal Kram 02/NS/94 of July 20,1994 Promulgating the law on the Organization and Functioning of the Council of Ministers.
- Having seen the Royal Degree No 14 ANKR.BK of March 03,1998 on the Organization and Functioning of the Ministry of Public Works and Transport.
- On the proposal of the Minister of Public Works and Transport

THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith to H.E.Mr. TRAM IV TEK, Secretary of State, Ministry of Public Works and Transport the full powers to sign, on behalf of the Royal Government of Cambodia, the Annexes and a Protocol for implementing the GMS Agreement on Cross-Border Transport Facilitation of Goods and People as follows:

1- Annex 2 : Registration of Vehicles in International Traffic
2- Annex 4 : Facilitation of Frontier Crossing Formalities
3- Annex 7 : Road Traffic Regulation and Signage
4- Annex 11 Road and Bridges Design and Construction Standards and Specifications
5- Annex 12 Border crossing and transit Facilities and Services
6- Annex 13a Multi-modal Carrier liability regime
7- Annex 15 Commodity Classification System
8- Protocol 1 Designation of Corridors, Routes, and Points of Entry and Exit(Border Crossings),
9- Amendment to Article 17 of the GMS Agreement on Cross-Border Transport Facilitation of Goods and People ;

on the occasion of the Inception Meeting of The Joint Committee of The GMS Cross-Border Transport Agreement, including signing of Stage 1 Annexes and Negotiation Meeting of Stage 2 Annexes, which will be held on 27-30 April 2004, in Phnom Penh.

In witness whereof, the Prime Minister of the Kingdom of Cambodia, has signed this delegation of full powers.

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៨ សព្រ

រាជធានីភ្នំពេញ ថ្ងៃទី ០៩- ខែ ធ្នូ ឆ្នាំ២០០៤

សិទ្ធិប្រទាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាឱ្យដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ អនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមិនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមសំណើរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

ប្រទានសិទ្ធិ ជូនឯកឧត្តម **ឃី តាំងលីម** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកជារដ្ឋមន្ត្រី អមមហាអនុតំបន់ទន្លេមេគង្គ ដើម្បីចុះហត្ថលេខាក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា លើឧបសម្ព័ន្ធសំរាប់ អនុវត្តកិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ដូចខាងក្រោម :

១-ឧបសម្ព័ន្ធទី១ : ស្តីអំពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់
២-ឧបសម្ព័ន្ធទី៩ : ស្តីអំពីលក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់អាជ្ញាប័ណ្ណ ដល់ប្រតិបត្តិការដឹកជញ្ជូនសំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
៣-ឧបសម្ព័ន្ធទី១៣បេ : ស្តីអំពីលក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់អាជ្ញាប័ណ្ណ ដល់ប្រតិបត្តិការដឹកជញ្ជូនតាមបែបពហុរូបភាព សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន
៤--ឧបសម្ព័ន្ធទី១៦ : ស្តីអំពីលក្ខណៈវិនិច្ឆ័យសំរាប់ការផ្តល់អាជ្ញាប័ណ្ណបើកបរយានយន្ត

ក្នុងឱកាសនៃកិច្ចប្រជុំលើកទី១៣ ថ្នាក់រដ្ឋមន្ត្រី GMS នៃកិច្ចសហប្រតិបត្តិការមហាអនុតំបន់ទន្លេមេគង្គ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០០៤ ខាងមុខនៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាមានិត ប្រជាធិបតេយ្យឡាវ ។

ដើម្បីជាសក្ខីភាព នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានចុះហត្ថលេខា លើសិទ្ធិប្រទាននេះ ។

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
Kingdom of Cambodia

រាជរដ្ឋាភិបាលកម្ពុជា
Royal Government of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

No: 58 D.F.P

Phnom Penh, December 06 2004

DELEGATION OF FULL POWERS

- Having seen the Constitution of the Kingdom of Cambodia;
- Having seen the Royal Kram NS/RKM/0704/ dated 13 July 2004, Promulgating the Law on Additional Constitution aiming at normalizing the functioning of the national institutions;
- Having seen the Royal Decree NS/RTK/0704/124 of July 15, 2004 on the Formation of the Royal Government of Cambodia;
- Having seen the Royal Kram 02/NS/94 of July 20,1994 Promulgating the law on the Organization and Functioning of the Council of Ministers;
- Having seen the Royal Degree No 14 ANKR.BK of March 03,1998 on the Organization and Functioning of the Ministry of Public Works and transport;
- On the proposal of the Minister of Public Works and Transport;

THE ROYAL GOVERNMENT OF CAMBODIA

Delegates herewith full power to H.E.Mr. KHY TAINGLIM, Senior Minister-Minister in charge of GMS , the full powers to sign, on behalf of the Royal Government of Cambodia, the Annexes for implementing the GMS Agreement on Cross-Border Transport Facilitation of Goods and Poeple as follows:

1- Annex1 : Carriage of dangerous Goods
2- Annex 9 : Criteria for Licensing of Transport Operators for Cross-Border Transport Operation
3- Annex 13b : Criteria for Licensing of Multimodal Transport Operators for Cross-Border Transport Operation
4- Annex 16 : Criteria for Driving Licensee

on the occasion of the 13th GMS Ministerial Conference to be held on 16 December 2004, in Vientiane ,Lao People Democratic Republic .

In witness whereof the undersigned, the Prime Minister of the Royal Government of Cambodia, has signed this delegation of full powers.

Prime Minister

HUN SEN

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

<u>(សេចក្តីព្រាង) សេចក្តីថ្លែងហេតុ</u>

នៃសេចក្តីព្រាងច្បាប់ ស្តីពី

<u>ការអនុម័តយល់ព្រមលើឧបសម្ព័ន្ធឧបសម្ព័ន្ធទី ១,២,៤,៧,៩, ១១,១២, ១៣អា ,១៣បេ,១៥ ,១៦</u>

<u>និងពិធីសារទី១ សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS</u>

<u>ស្តីពីការសំរួលការដឹកជញ្ជូនទំនិញ និងប្រជាពលរដ្ឋ ឆ្លងកាត់ព្រំដែន</u>

<u>សេចក្តីផ្តើម</u>

កិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាល សាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋ ឆ្លងកាត់ព្រំដែន បានចុះហត្ថលេខាជាលើកដំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅ ទីក្រុងវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ នៅទីក្រុងយ៉ាងហ្គូន . ដែលបានយល់ព្រមចូលដោយ ព្រះរាជាណាចក្រកម្ពុជានៅទីក្រុងយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយ សាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅទីក្រុងភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី ខេត្តយូណាន់ សាធារណរដ្ឋ ប្រជាមានិតចិន ។ ច្បាប់ស្តីពីកាអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងនិងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាធិប តេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីការសម្រួលនូវការដឹកជញ្ជូន ទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែនត្រូវបានរដ្ឋសភានៃ ព្រះរាជាណាចក្រកម្ពុជា បានអនុម័តរួចហើយ កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលជាកិច្ចព្រមព្រៀងក្របខ័ណ្ឌ ហើយត្រូវបានប្រកាសរួចហើយដែរ ដោយព្រះរាជក្រមលេខ នស/រកម/០១០៣/០០២ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣។

ក្នុងមាត្រាទី ៣(បេ)និង(អិន)នៃកិច្ចព្រមព្រៀង បានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា។ យោងតាមមាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានតេធ្វើវិសោធនកម្មរួចហើយ បានបញ្ជាក់ថាឧបសម្ព័ន្ធ និងពិធីសារ នីមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង។

ក្នុងឱកាសនៃកិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០, កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទិ១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ រដ្ឋមន្ត្រី GMS ទាំងអស់ <u>*បានឯកភាពយល់ព្រមទៅនឹងផែនការការងាររួមយ ក្នុងការបង្ហើយ-បញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសារ របស់វា ព្រមទាំងអនុវត្តឧបសម្ព័ន្ធ-ពិធីសារទាំងនេះ នៅចុងឆ្នាំ ២០០៥*</u>។ ឧបសម្ព័ន្ធ និងពិធីសារទាំងអស់នេះ បានចុះហត្ថលេខាជាបន្តបន្ទាប់រៀងៗគ្នា ក្នុងឱកាសកិច្ចប្រជុំលើកទី១ គណៈកម្មការរួម GMS សំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន កាលពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៤ នៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា និងក្នុងឱកាសនៃកិច្ចប្រជុំលើកទី១៣ រដ្ឋមន្ត្រី GMS កាលពីថ្ងៃទី ១៦ខែធ្នូ ឆ្នាំ ២០០៤ នៅទីក្រុងវៀងច័ន្ទ សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ។ ផលប្រយោជន៍នៃឧបសម្ព័ន្ធ និងពិធីសារទាំងអស់នេះមាន :

- អនុញ្ញាតឱ្យកម្ពុជា ចូលរួមក្នុងការដឹកជញ្ជូន និងពាណិជ្ជកម្មឆ្លងកាត់ព្រំដែន និងសមាហរណកម្មតំបន់.
- ជួយសំរួល និងជំរុញវិស័យដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងពាណិជ្ជកម្មអន្តរជាតិ ពិសេសនៅពេលដែលកម្ពុជានៅពុំទាន់មានច្បាប់ដឹកជញ្ជូនឆ្លងកាត់ព្រំដែន និងពាណិជ្ជកម្មអន្តរជាតិឱ្យបានរឹងមាំ គ្រប់គ្រាន់នៅឡើយ.
- បង្កើតការងារ និងបង្កើនការវិនិយោគបន្ថែម សំរាប់ចរាចរដឹកជញ្ជូនឆ្លងកាត់ ទេសចរ និងពាណិជ្ជកម្មអន្តរជាតិ

១. វិសោធនកម្មនៃមាត្រាទី១៧ នៃកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសម្រួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

វិសោធនកម្មមាត្រាទី១៧ នៃកិច្ចព្រមព្រៀងខាងលើ មាន៤មាត្រា ពាក់ព័ន្ធទៅនឹងការកែសំរួលមាត្រា១៧ ដែលតំរូវឱ្យភាគីចុះកិច្ចសន្យាត្រូវទទួលស្គាល់ទៅវិញទៅមកនូវប័ណ្ណបើកបរដែលចេញឱ្យដោយអជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដោយអនុលោមទៅតាមឧបសម្ព័ន្ធទី១៦ ដែលត្រូវរៀបចំថ្មីបន្ថែមទៀត។ ការធ្វើវិសោធនកម្មនេះគឺដោយយោងទៅលើមាត្រាទី២ នៃអនុស្សារណៈនៃកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលបានចុះហត្ថលេខានៅភ្នំពេញនៅថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០២ ដែលសន្យាធ្វើវិសោធនកម្មមាត្រាទី៧(ប័ណ្ណបើកបរ) នៃកិច្ចព្រមព្រៀងដើម្បីអនុញ្ញាតឱ្យសាធារណរដ្ឋប្រជាមានិតចិន(ដែលមិនមែនជាសមាជិកអាស៊ាន) អាចចូលក្នុងកិច្ចព្រមព្រៀងបាន។ក្នុងមាត្រា១៧(ចាស់) នៃកិច្ចព្រមព្រៀងបញ្ជាក់ថាភាគីកិច្ចសន្យាទាំងអស់(ដែលជាសមាជិកអាស៊ាន) ត្រូវទទួលស្គាល់ប័ណ្ណបើកបរទៅវិញទៅមកដោយអនុវត្តនិងអនុលោមទៅតាមកិច្ចព្រមព្រៀងអាស៊ាន ស្តីអំពីការទទួលស្គាល់ប័ណ្ណបើកបរទៅវិញទៅមកដែលចេញឱ្យ ដោយប្រទេសជាសមាជិកអាស៊ាន ដែលបានចុះហត្ថលេខានៅឆ្នាំ ១៩៩៨។ វិសោធនកម្មនេះតំរូវឱ្យបញ្ចូលនៅក្នុងតារាងឧបសម្ព័ន្ធ និងពិធីសារ ដែលភ្ជាប់ជាមួយកិច្ចព្រមព្រៀងនូវឧបសម្ព័ន្ធថ្មីមួយឧបសម្ព័ន្ធទី១៦:លក្ខណៈវិនិច្ឆ័យ សំរាប់ការផ្តល់ប័ណ្ណបើកបរ។

២. ឧបសម្ព័ន្ធទី ២ :ការចុះបញ្ជីយានយន្ត នៅក្នុងចរាចរអន្តរជាតិ

ឧបសម្ព័ន្ធទី២នេះមាន១៨មាត្រា និងមានឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី២: គំនូសជ្យាក្រាមនៃយានយន្តទាំងឡាយ ពាក់ព័ន្ធទៅនឹងលក្ខណៈសំគាល់យានយន្តជាទូទៅ និងមានខ្លឹមសារសំខាន់ៗ ដូចជា :ការកំណត់ប្រភេទយានយន្ត(ឧបសម្ព័ន្ធនេះខុសពីពិធីសារអាស៊ាន ដោយអាស៊ានអនុញ្ញាតត្រឹមតែរថយន្តដឹកទំនិញ ប៉ុន្តែឧបសម្ព័ន្ធ GMS នេះ អនុញ្ញាតទាំងរថយន្តដឹកទំនិញ ដឹកអ្នកដំណើរ និងរថយន្តផ្ទាល់ខ្លួន) ក្នុងនោះមានករណីកិច្ចនៃការចុះបញ្ជី, ការប្រើប្រាស់ភាសា និងតួអក្សរជាភាសាអង់គ្លេស និងជាលេខអារ៉ាប់នៅលើផ្លាកលេខនិងប័ណ្ណចុះបញ្ជី សញ្ញាសំគាល់យានយន្ត(ម៉ាក)ដូចជាឈ្មោះឬ និមិត្តសញ្ញាពាណិជ្ជកម្មនៃរោងចក្រផលិតយានយន្ត លេខផលិតផលរបស់រោងចក្រ ឬលេខស៊េរីរបស់យានយន្ត និងលេខម៉ាស៊ីន។ល។ ប្រភេទនិងលក្ខណៈពិសេសៗនៃផ្លាកលេខចុះបញ្ជី វិញ្ញាបនប័ត្រនៃការចុះបញ្ជី (ប័ណ្ណចុះបញ្ជីឬប័ណ្ណសំគាល់យានយន្ត):ដែលមានសុពលភាព និងសញ្ញាសំគាល់លក្ខណៈជាតិ :សំរាប់កម្ពុជា: KH សាធារណរដ្ឋប្រជាមានិតចិន: CHN សាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ:LAO មីយ៉ាន់ម៉ា: MYA ថៃឡង់ដ៍ : T វៀតណាម : VN ។

៣.ឧបសម្ព័ន្ធទី ៤ : ការសំរបសំរួលបែបបទឆ្លងកាត់ព្រំដែន

ឧបសម្ព័ន្ធទី៤នេះមាន ២១មាត្រា (និងមានឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី២ : ជាគំនូសបង្ហាញជាគន្លឹះ របស់អង្គការសហប្រជាជាតិ សំរាប់ឯកសារខាងពាណិជ្ជកម្ម(United Nations Layout Key for Trade Documents)) ដែលពាក់ព័ន្ធទៅនឹងរាល់បែបបទនិតិវិធីសំរួលការត្រួតពិនិត្យគយ អន្តោប្រវេសន៍ និងសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀតតាមច្រកព្រំដែន ឱ្យបានឆាប់រហ័ស ងាយស្រួល មានប្រសិទ្ធភាពនិងត្រូវគ្នា ស៊ីចង្វាក់គ្នាជាទូទៅ ទៅលើគ្រប់ចលនាដឹកជញ្ជូនឆ្លងកាត់ព្រំដែននូវមនុស្សម្នា យានយន្ត និងទំនិញតាមផ្លូវគោក ដែលជាផ្នែកមួយនៃការដឹកជញ្ជូនតាមបែបពហុភាព រាប់ទាំងពេលម៉ោងប្រតិបត្តិការ ប្រភេទសេវាកម្មត្រួតពិនិត្យ (គយ, ភូតគាមអនាម័យ, ការត្រួតពិនិត្យ/ការឆែកឆេរគុណភាព, សុខភាព, អន្តោប្រវេសន៍...) ។ល។ ក្នុងនោះមានការកំណត់ប្រភេទទំនិញ តំរូវការមន្ត្រីប្រចាំការនៅជាអចិន្ត្រៃយ៍ ឬតាមរយៈការស្នើសុំឱ្យមានការបើកព្រំដែននិងការជំរះបែបបទនៅក្រៅម៉ោងធ្វើការការងារធម្មតា ការធ្វើអោយចុះសំរុងគ្នានូវមធ្យោបាយឧបករណ៍ខាងអេឡិចត្រូនិក ឬក៏មធ្យោបាយទំនាក់ទំនងផ្សេងទៀត រួមទាំងគ្រឿងប្រដាប់ដើម្បីកត់ត្រាទិន្នន័យ, និងកម្មវិធីផ្នែកទន់(Software) ជាមួយនឹងប្រព័ន្ធទាំងឡាយដែលកំពុងប្រើប្រាស់ ឬដែលបានប្តូរផ្លាស់និងកែលំអអោយទាន់សម័យ។

<u>ផ្សេងពីការអនុវត្តន៍ក្នុងអាស៊ាន ក្រុមប្រទេសក្នុងតំបន់ GMS បានឯកភាពគ្នាកំណត់ និងអនុវត្តការសំរបសំរួលការត្រួតពិនិត្យតាមច្រកព្រំដែន ដែលមានការកត់សំគាល់ពិសេសដូចខាងក្រោម :</u>

*ការអនុវត្តការត្រួតពិនិត្យរួមគ្នាបង្អួច(ឬបញ្ជរ)តែមួយ*គឺជានិតិវិធីក្នុងការឆែកឆេរនិងការត្រួតពិនិត្យក្នុងពេលព្រម ១ ភ្នាបង្អួចតែមួយ(ឬបញ្ជរ)តែមួយ ពីគ្រប់អជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ទៅលើមនុស្សម្នា ទំនិញ និងយានយន្ត។ អជ្ញាធរដទៃទៀតអាចផ្ទេរសមត្ថកិច្ចការងាររបស់ពួកខ្លួន ជូនទៅអជ្ញាធរមួយទៀត ដែលមានវត្តមាន ប្រចាំនៅច្រកព្រំដែន(ឧ. ជូនអជ្ញាធរគយត្រួតពិនិត្យយានយន្ត) ។ល។

ការត្រួតពិនិត្យគយរួមគ្នាតែមួយលើក(ឈប់តែម្តង): គឺជាប្រតិបត្តិការនៃការត្រួតពិនិត្យគយតែមួយលើកគត់សំរាប់ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន រវាងពីរប្រទេសដែលស្រុះស្រួលគ្នា។ មានការស្នើឡើងនូវបែបផែនជាគំរូ (Suggested Modalities) សំរាប់ការត្រួតពិនិត្យគយរួមគ្នាតែមួយលើក ដូចខាងក្រោម :

១- **ការរៀបចំការត្រួតពិនិត្យរួមគ្នា :** អជ្ញាធរគយជាតិរវាងពីរភាគីដែលស្រុះស្រួលគ្នា ត្រូវអនុវត្តការត្រួតពិនិត្យ និងការឆែកឆេររួមគ្នា និងព្រមពេលដំណាលគ្នា ។

២- **ការរៀបចំដាច់ដោយឡែកពីគ្នា :**អជ្ញាធរគយពីភាគីចុះកិច្ចសន្យាមួយរៀបចំជំនាញពិសេសក្នុងការងារ ពិសេសណាមួយ នៅពេលដែលអជ្ញាធរគយពីភាគីចុះកិច្ចសន្យាមួយផ្សេងទៀត រៀបចំជំនាញពិសេស សំរាប់ការងារផ្សេងណាមួយទៀត ជាឧទាហរណ៍ទៅតាមប្រភេទទិសដៅចរាចរ(ទិសដៅចេញក្រៅ ឬទិសដៅចូលក្នុង) ឬក៏ប្រភេទនៃការដឹកជញ្ជូន (អ្នកដំណើរ ឬទំនិញ) ។

៣- **សកម្មភាពនៅលើទឹកដីប្រទេសដទៃផ្សេងទៀត:**មន្ត្រីគយពីភាគីចុះកិច្ចសន្យាមួយអាចអនុញ្ញាតឱ្យ ធ្វើសកម្មភាពការងាររបស់ពួកគេ នៅលើទឹកដីនៃភាគីចុះ កិច្ចសន្យាផ្សេងទៀត។

៤- **ការផ្ទេរសិទ្ធិនៃអជ្ញាធរ /ការទទួលស្គាល់ទៅវិញទៅមកនូវការត្រួតពិនិត្យ :** ភាគីចុះកិច្ចសន្យាមួយអាចផ្ទេរសិទ្ធិខាងសមត្ថកិច្ចនៃការត្រួតពិនិត្យនិងការឆែកឆេររបស់ខ្លួនទៅឱ្យមន្ត្រីគយនៃភាគីចុះកិច្ចសន្យា ដែលស្រុះស្រួលគ្នាមួយផ្សេងទៀតដើម្បីធ្វើសកម្មភាពនៅក្នុងនាមរបស់ខ្លួន។ ភាគីចុះកិច្ចសន្យាត្រូវទទួលស្គាល់គ្នាទៅវិញទៅមកការត្រួតពិនិត្យឆែកឆេរ ដោយអជ្ញាធរគយនិមួយៗ នៃភាគីផ្សេងទៀត។

៥- **ការរួមបញ្ចូលគ្នា:** ការរួមបញ្ចូលគ្នានៃបែបផែនជាគំរូ ដូចរៀបរាប់ខាងលើក៏អាចអនុវត្តបានផងដែរ។

៦-**ការអនុវត្តន៍ដោយរៀបចំឱ្យមានជាអនុស្សារណៈនៃកិច្ចព្រមព្រៀង(MOU)** លើរាល់បែបផែនជាគំរូពិសេស ស្តីពីនិតិវិធីនៃការត្រួតពិនិត្យគយរួមគ្នាតែមួយលើក នឹងត្រូវព្រមព្រៀងគ្នាដោយភាគីមានព្រំដែនជាប់គ្នា ។

ក្រៅពីនេះមានការធ្វើឱ្យស៊ីចង្វាក់គ្នា ការធ្វើឱ្យងាយស្រួលសាមញ្ញក្នុងការប្រើប្រាស់ភាសាលើរាល់ឯកសារទាំងឡាយ ការផ្លាស់ប្តូរគ្នាពត៌មានអំពីបទបញ្ញត្តិច្បាប់ ទំរង់បែបបទនិតិវិធីនិងការអនុវត្តន៍ និងការផ្លាស់ប្តូរទំរង់បែបបទឆ្លងកាត់ព្រំដែន ការប្តូរគ្នាជាមុននូវពត៌មាននៃការជំរះបែបបទនៅមុនគ្រាមកដល់នៃទំនិញ ការកំណត់លំដាប់អាទិភាពនៃការជំរះបែបបទឆ្លងកាត់ព្រំដែន ការកាត់បន្ថយនូវការអនុវត្តន៍ការត្រួតពិនិត្យរូបវន្ត(ជាក់ស្តែង) អត្ថិភាពនិងតំរូវការខាងមធ្យោបាយ និងមន្ត្រី ដែលមានសមត្ថភាព ។ល។ និង ។ល។

៤-ឧបសម្ព័ន្ធទី ៧ : បទបញ្ញត្តិចរាចរតាមផ្លូវថ្នល់ និងផ្លាកសញ្ញា

ឧបសម្ព័ន្ធទី៧នេះមាន១៣មាត្រា(និងមានឯកសារចំនួន០២ភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី៧:ឯកសារភ្ជាប់ទី១: **បទបញ្ជាចរាចរតាមផ្លូវថ្នល់** និងឯកសារភ្ជាប់ទី២: **ផ្លាកសញ្ញា និងភ្លើងសញ្ញាចរាចរតាមផ្លូវថ្នល់** ដែលពាក់ព័ន្ធទៅនឹងការអនុវត្តទៅតាមសិទ្ធិសញ្ញាអន្តរជាតិស្តីអំពី **បទបញ្ជាចរាចរតាមផ្លូវថ្នល់** និង**ផ្លាកសញ្ញា និងភ្លើងសញ្ញាចរាចរតាមផ្លូវថ្នល់**របស់UNESCAP និងមានខ្លឹមសារ សំខាន់ៗ ផ្សេងទៀតដូចខាងក្រោម ដូចជា:

-ការកំណត់រយៈពេលអន្តរកាល(បណ្តោះអាសន្ន)មួយ មានរយៈពេល ៤ឆ្នាំ ដែលតំរូវឱ្យមានការផ្លាស់ប្តូរ ឬដាក់បន្ថែមនូវផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញានានានៅតាមដងផ្លូវ និងផ្លូវរបៀងមេ(ដែលបានកំណត់ក្នុងពិធីសារទី១ នៃកិច្ចព្រមព្រៀង) ដែលដូចគ្នាទៅនឹងផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា ឬគំនូស សញ្ញាទាំងឡាយដែលមានបញ្ញត្តិនៅក្នុងឯកសារភ្ជាប់ទី២នៃឧបសម្ព័ន្ធនេះ ប៉ុន្តែវាមានអត្ថន័យផ្សេងពីគ្នា។

-ការកំណត់រយៈពេលអន្តរកាល(បណ្តោះអាសន្ន)មួយ មានរយៈពេល១៥ឆ្នាំ ដែលតំរូវឱ្យមានការផ្លាស់ប្តូរ ឬដាក់បន្ថែមនូវផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញានានានៅតាមដងផ្លូវ និងផ្លូវរបៀងនានា ដែលបានកំណត់ក្នុងពិធីសារទី១នៃកិច្ចព្រមព្រៀង ដែលផ្លាកសញ្ញា និមិត្តសញ្ញា ភ្លើងសញ្ញា និងគំនូសសញ្ញាដើមទាំងអស់នោះ

មិនមានបញ្ញត្តិនៅក្នុងឯកសារភ្ជាប់ទី២នៃឧបសម្ព័ន្ធនេះ ។*ផ្លាកសញ្ញា និងនិមិត្តសញ្ញាថ្មីទាំងឡាយដូចមានបញ្ញត្តិ នៅក្នុង ឯកសារភ្ជាប់ទី២នោះ អាចគំឡើងឱ្យនៅក្បែរ ផ្លាកសញ្ញា និងនិមិត្តសញ្ញាដើមនានាដែលមានស្រាប់*។

-ការអនុញ្ញាតជាចំហក្នុងការប្រើប្រាស់នូវផ្លាកសញ្ញា និមិត្តសញ្ញា ឬគំនូសសញ្ញាផ្សេងទៀតដែល មិនមានបញ្ញត្តិនៅក្នុងឯកសារភ្ជាប់ទី២ នៃឧបសម្ព័ន ទៅតាមតំរូវការ ។

-ឧបសម្ព័ន្ធនេះមិនបានតំរូវឱ្យគេអនុម័តទទួលយកផ្លាកសញ្ញានិងគំនូសសញ្ញា ដែលបានបញ្ញត្តិដោយឯកសារភ្ជាប់ទី២ ទាំងអស់នោះទេ។ ផ្ទុយទៅវិញគេអាចកំរិតនូវចំនួន និងប្រភេទនៃផ្លាកសញ្ញា ឬគំនូសសញ្ញាទាំងឡាយណាដែលពួកគេត្រូវការ និងអនុម័តយល់ព្រមទទួលយកនូវអ្វីដែល ចាំបាច់ខានមិនបានតែប៉ុណ្ណោះ ។

-ការហាមឃាត់មិនឱ្យមានការសរសេរ ឬដាក់(តំលើង)បន្ថែម ឧបករណ៍ សំភារៈ ការផ្សព្វផ្សាយពាណិជ្ជកម្ម ផ្លាកជូនដំណឹង គំនូសសញ្ញា ឬឧបករណ៍ដទៃទៀត ឱ្យស្ថិតនៅជិតឬក្បែរផ្លាកសញ្ញា ឬឧបករណ៍ត្រួតពិនិត្យចរាចរ ដែលធ្វើអោយផ្លាកសញ្ញាទាំងនោះមិនអាចសំគាល់បាន ឬធ្វើអោយយល់ច្រលំនឹងធ្វើឱ្យមានគ្រោះថ្នាក់ ឬធ្វើអោយវង្វេងស្មារតីដល់អ្នកប្រើប្រាស់ផ្លូវថ្នល់ ដែលបង្កនិងធ្វើអោយខូច ប្រយោជន៍ ដល់សុវត្ថិភាពចរាចរ ។ល។

- ត្រូវប្រើប្រាស់រូបសញ្ញានានាជំនួសឱ្យបានច្រើនជាង ការប្រើប្រាស់ភាសា(អក្សរ)សរសេរក្នុងផ្លាកសញ្ញាចរាចរ
- ការប្រើប្រាស់ភាសារអង់គ្លេស/ឡាតាំង លេខអារ៉ាប់ និងភាសាជាតិព្រមគ្នា/ស្របគ្នា ក្នុងការអធិប្បាយផ្លាកសញ្ញា គំនូសសញ្ញាផ្លូវថ្នល់ ផ្សេងទៀតទាំងឡាយ ។ល។ និង ។ល។

៥. ឧបសម្ព័ន្ធទី១១:បទដ្ឋាន ឬមាត្រដ្ឋាន(ស្តង់ដារ) និងលក្ខណៈបច្ចេកទេស សំរាប់ការគូសប្លង់ និងសាងសង់ផ្លូវ ស្ពាន

ឧបសម្ព័ន្ធទី១១នេះមាន ២១មាត្រា ដែលំពាក់ព័ន្ធទៅនឹងការអនុវត្ត ការរៀបចំជាបទដ្ឋាន មាត្រដ្ឋាន ស្តង់ដារ និងលក្ខណៈបច្ចេកទេសសំរាប់ការគូសគំរោងប្លង់និងសាងសង់ផ្លូវ-ស្ពាន នៅលើផ្លូវហាយវេយតំបន់ទាំងអស់ ។ តារាងបទដ្ឋាន-ស្តង់ដារផ្លូវ គឺប្រហាក់ប្រហែលទៅនឹង តារាងបទដ្ឋាន-ស្តង់ដារផ្លូវរបស់ អាស៊ាន ឬរបស់ហាយវេយអាស៊ី(ESCAP)។ ចំណុចខុសគ្នានៅត្រង់ថា ស្តង់ដារផ្លូវនេះអនុលោមទៅតាមស្តង់ដារផ្លូវ-ស្ពាន នៅប្រទេសចិន ដែលទាបជាងស្តង់ដារផ្លូវអាស៊ាននៅចំណុចខ្លះ ដូចជាទទឹងថ្នល់ ទទឹងខ្សែរចរាចរ ឬប្រឡោះលំហ ស្ពានជាដើម ដែលនេះជាការល្មមល្មៀង សំរាប់ស្តង់ដារផ្លូវតូចៗនៅកម្ពុជា។

ឧបសម្ព័ន្ធត្រូវបានគេកំនត់ផងដែរ នូវនិយមន័យ ការចាត់ថ្នាក់នៃផ្លូវនិងនិងរបៀងកណ្តាល (ឬរបៀងមេ)ទាំងឡាយ ដែលបានកំណត់ក្នុងពិធីសារទី១នៃកិច្ចព្រមព្រៀង ចំណាត់ថ្នាក់(ដូចជាៈ ផ្លូវកំរិតចំបង ផ្លូវថ្នាក់ទី១ ផ្លូវថ្នាក់ទី២ ផ្លូវថ្នាក់ទី៣) និងតួនាទីខាងចរាចរ សំរាប់ចំណាត់ថ្នាក់ និងប្រភេទផ្លូវទាំងអស់នេះ។ ឧទាហរណ៍"ផ្លូវកំរិតចំបង " ឬផ្លូវធំម៉ូតូវេយត្រូវមានរបងការពារនិងប្រើប្រាស់បានតែរថយន្តគ្រប់ប្រភេទ ហើយផ្លូវចូលទៅផ្លូវម៉ូតូវេយ ផ្លូវឆ្លងកាត់ ផ្លូវរថភ្លើងឆ្លងកាត់ ដែលត្រូវបំបែកឱ្យនៅដាច់ និងមានកំរិតកំពស់ផ្សេងពីគ្នា។ ម៉ូតូ កង់ និងអ្នកថ្មើរជើងនឹងមិនត្រូវបានគេអនុញ្ញាត ឱ្យធ្វើដំណើរជាមួយនឹងផ្លូវរថយន្ត-ម៉ូតូវេយទេ ក្នុងគោលបំណងដើម្បីធានាសុវត្ថិភាពចរាចរ និងសុវត្ថិភាពយានយន្ត ដែលមានល្បឿនលឿន ហើយទ្រូងផ្លូវត្រូវចែកដាច់ពីគ្នា ដោយមានគំនូសទ្រូងផ្លូវ ។ ល។

ភាគីនិមួយៗអាចសាងសង់និងប្រើប្រាស់បាន *ផ្លូវកំរិតទី៣(ដែលជាផ្លូវមានកំរិតស្តង់ដារទាបបំផុតសំរាប់ចរាចរឆ្លងកាត់ព្រំដែន)* នៅពេលដែលមូលនិធិសំរាប់ការសាងសង់ និងដែល/រឺក៏ដីសំរាប់សាងសង់ផ្លូវមានកំរិត ហើយត្រូវជំរុញការលើកកំពស់ផ្លូវឬកំណាត់ផ្លូវទាំងឡាយណា ដែលនៅក្រោមកំរិតនេះ ឱ្យឡើងដល់បទដ្ឋានកំរិតទី៣ ក្នុងពេលឆាប់ៗនាថ្ងៃអនាគត។

ការរៀបចំនឹងបំពាក់នូវគ្រឿងប្រដាប់ឧបករណ៍នៅតាមផ្លូវថ្នល់ទៅតាមកន្លែងសំខាន់ៗ ស្របតាមចំណាត់ថ្នាក់ នៃផ្លូវ Highway ដូចជាៈ ការតុបតែងភ្លើងបំភ្លឺ គ្រឿងឧបករណ៍ប្រឆាំងនឹងការចាំងពន្លឺ (ដូចជារបាដែកមេដ្យានពុះទ្រូងផ្លូវ) របាំង-សំណាញ់សិប្បនិមិត្ត ឬរបងកូនឈើនៅលើគំនូសចែកកណ្តាលផ្លូវ ឬគំនូសចិញ្ចើមផ្លូវដើម្បីបាំងការពារចំណែកផ្លូវ ឬទ្រូងផ្លូវទៅតាមចរាចរបញ្ច្រាសទិសគ្នា ឬពីផ្លូវដែលស្របគ្នា គំនូសសំរាប់បញ្ឈប់យានយន្តពេលមានគ្រោះបន្ទាន់ បន្ទះឬខ្សែរការពារ ឬបង្គោលទំនប់ នៅតាមបណ្តោយជម្រាល ឬចំណោតភ្នំ របងសុវត្ថិភាពនិងរបាំងការពារពេលមានគ្រោះថ្នាក់ របងការពារពីការឆ្លងកាត់របស់សត្វពាហនៈ បន្ទប់ឬបញ្ជរទូរស័ព្ទទំនាក់ទំនងបន្ទាន់ មធ្យោបាយសម្បទា សេវាកម្មបំរើ និង កន្លែងឈប់

សំរាកទាំងឡាយផ្សេងទៀតដូចជាទីធ្លា ចំណតរថយន្ត ស្ថានីយប្រេង និងស្ថានីយជួសជុលថែទាំយានយន្ត មជ្ឈមណ្ឌលទូរគមនាគមន៍ បរិក្ខារអនាម័យ (បង្គន់) សណ្ឋាគារ ផ្ទះសំណាក់ ភោជនីយដ្ឋាន) នៅតាមដងផ្លូវ ។ល។

៦. ឧបសម្ព័ន្ធទី១២ : មធ្យោបាយសម្បទា និងសេវាបំរើ សំរាប់ការឆ្លងកាត់ និងការឆ្លងព្រំដែន

ឧបសម្ព័ន្ធទី១២នេះមាន ១៣មាត្រា ពាក់ព័ន្ធទៅនឹងអត្ថិភាព និងតំរូវការ ជាមធ្យោបាយសម្បទា សេវាបំរើ បរិធាន ឬឧបករណ៍ ឬមធ្យោបាយនិងសម្បទាផ្សេងទៀត នៅចំណុចប៉ុស្តិ៍ឆ្លងកាត់ព្រំដែន សំរាប់បំរើដល់យានយន្ត ទំនិញ អ្នកបើកបរ អ្នកធ្វើដំណើរ ក្នុងការឈប់សំចត ការរង់ចាំ ឬការបំពេញបែបបទសំរាប់ការដឹកជញ្ជូន និងការឆ្លងកាត់ព្រំដែន និងមានខ្លឹមសារសំខាន់ៗ ដូចជា: សេវាជួសជុល និងថែទាំយានយន្ត ស្ថានីយប្រេងឥន្ធនៈ ទីចំណតយានយន្ត ឬទីលានដែលមានកំរាលរឹង(កំរាលបេតុង) និងមធ្យោបាយ-សម្បទាផ្សេងទៀតសំរាប់ជួយសំរួលការលាងសំអាតយានយន្ត តំបូលគ្របការពារក្នុងពេលផ្លាស់ប្តូរអាកាសធាតុ ពេលផ្ទុក-ផ្ទេរ លើកដាក់ទំនិញ ពេលវេចខ្ចប់និងបញ្ជូនទំនិញ និងពេលត្រួតពិនិត្យទំនិញ ។ល។ ឃ្លាំង ឬបន្ទប់ស្តុកទុកនិងរក្សាទំនិញ (រាប់ទាំងទីកន្លែងដែលមានបំពាក់ម៉ាស៊ីនត្រជាក់) ស្ថានីយកុងតឺណឺ (និងមធ្យោបាយផ្សេងទៀតសំរាប់ស្តុកទុកទំនិញ ក្នុងពេលរង់ចាំ ឬកកស្ទះ ពេលបើក ឬការបើកឡើង សំរាប់ ការត្រួតពិនិត្យខាងអនាម័យ និងបសុពេទ្យ ឬភូតគាមានាម័យ ឬការដាក់ឱ្យនៅដាច់ពីគេ) ។ល។ ឃ្លាំងគយ , មធ្យោបាយ ឧបករណ៍សំភារៈ ឬសម្បទា សំរាប់ការដាក់ឱ្យនៅដាច់ពីគេ (ភូតគាមអនាម័យ)រុក្ខជាតិ ការលាងជំរះសំអាតមេរោគ និងចំណុចឈប់ ឬកន្លែងសំចតជាដំណាក់ៗទាំងឡាយ ដែលអនុញ្ញាតឱ្យមានការសំរាក ការផ្គត់ផ្គង់ចំណីអាហារនិងទឹក ការដាក់ចុះ ការរៀបចំទីកន្លែងប្រគល់ទំនិញដែលជាសត្វរស់ និងមធ្យោបាយ-សម្បទា សំរាប់ការដាក់ឱ្យនៅ ដាច់ពីគេនូវសត្វរស់ ។ល។

ត្រូវបង្កើតឡើងឱ្យមានសេវាបំរើ មធ្យោបាយ-សម្បទា ឧបករណ៍សំភារៈ សំរាប់ការស្រាវជ្រាវ (ឆែក) រកមើលពត៌មានអ្នកធ្វើដំណើរ កន្លែងសំរាកកាយ ឧបករណ៍អនាម័យ(បង្គន់) និងថ្នាំជំនួយសុខភាពតំបូង មជ្ឈមណ្ឌលទំនាក់ទំនង (ប៉ុស្តិ៍ប្រៃសណីយ៍និងទូរគមនាគមន៍) បញ្ជូរផ្ញើរសំបុត្រនិងសេវាប្រៃសណីយ៍ (ទូរស័ព្ទ ទូរពុម្ព ទូរសារ អិនធើណែត) មជ្ឈមណ្ឌលពត៌មាន ការិយាល័យធនាគារនិងការប្តូរប្រាក់ប័ណ្ណ កំឡាំងប៉ូលីសនិងកំលាំងផ្សេងទៀត ដើម្បីធានាសុវត្ថិភាព និងសន្តិសុខដល់អ្នកបើកបរ អ្នកដំណើរ រថយន្ត និងទំនិញបរទេស នៅក្នុងពេលឈប់ ឬសំចត នៅប៉ុស្តិ៍ឬស្ថានីយឆ្លងកាត់ព្រំដែន ស្ថានីយថ្លឹងទំងន់រថយន្ត ស្ថានីយឬទីឈប់សំចត ឬចំណត ដែលកំណត់ឡើងដោយប្រទេសសាម៉ី និងអត្ថិភាព និងតំរូវការមន្ត្រីបុគ្គលិកដែល មានគុណភាព-សមត្ថភាព (ដែលមានចំណេះខាងភាសា អង់គ្លេស) ។ល។

ត្រូវសាងសង់ផងដែរ នូវចំណែកផ្លូវសំរាប់ប្តូរទិសប្រកាន់(ឆ្វេង-ស្តាំ) នៃចរាចរ នៅទីណាដែលមានតំរូវការ ។

រក្សានិងបន្តការប្រើប្រាស់ ការអភិវឌ្ឍន៍បច្ចេកវិទ្យា និងការអនុវត្តន៍បច្ចេកទេសទំនើប និងជឿនលឿន ដូចជាម៉ាស៊ីនត្រួតពិនិត្យវីអានលិខិតឆ្លងដែន ម៉ាស៊ីនប្រើកាំរស្មីអ៊ិចសំរាប់ត្រួតពិនិត្យទំនិញនិងកុងតឺណឺ ម៉ាស៊ីនស្វ័យប្រវត្តិសំរាប់ បញ្ជាក់លក្ខណៈយានយន្ត(ម៉ាស៊ីនសំរាប់អាននិងត្រួតពិនិត្យផ្លាកលេខចុះបញ្ជី) និងម៉ាស៊ីនសំរាប់អានរីត្រួតពិនិត្យបាកូដX-ray ។ល។

៧. ឧបសម្ព័ន្ធទី ១៣អា : របបគ្រប់គ្រងការទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាព

ឧបសម្ព័ន្ធទី១៣អានេះមាន ១០មាត្រា ពាក់ព័ន្ធទៅនឹង ច្បាប់ នីតិវិធីនិងរបបគ្រប់ ការទទួលខុសត្រូវរបស់អ្នកដឹកជញ្ជូនពហុភាព និងមានខ្លឹមសារដូចខ្លឹមសារនៃឯកសារភ្ជាប់នៃឧបសម្ព័ន្ធនេះ " របបទទួលខុសត្រូវអ្នកដឹកជញ្ជូនពហុភាព " ។

៨. ឧបសម្ព័ន្ធទី ១៥ : ប្រព័ន្ធចាត់ថ្នាក់ទំនិញ

ឧបសម្ព័ន្ធទី១៥នេះមាន ១៥មាត្រា(និងមាន ឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី១៥ : អនុសញ្ញាអន្តរជាតិ ប្រព័ន្ធចុះសំរុងគ្នានៃការពណ៌នានូវមុខទំនិញ (នាមការទំនិញ) និងប្រព័ន្ធលេខកូដ(របៀលិខ) (ទីក្រុងប្រ៊ុសែល ថ្ងៃទី ១៤ ខែមិថុនា ឆ្នាំ ១៩៨៣ ដែលបានធ្វើវិសោធនកម្ម តាមរយៈពិធីសារស្តីអំពីវិសោធនកម្មលើអនុសញ្ញាអន្តរជាតិ ស្តីអំពីប្រព័ន្ធចុះសំរុងគ្នានៃការពណ៌នានូវមុខទំនិញ (នាមការទំនិញ) និងប្រព័ន្ធលេខកូដ (របៀលិខ) នៅថ្ងៃ ២៤ ខែ មិថុនា ឆ្នាំ ១៩៨៦) ដែលពាក់ព័ន្ធទៅនឹងនិតិវិធី និង ការទទួលអនុវត្តតាមប្រពន្ធ័ចុះសំរុងគ្នា(H.S) ការប្រើប្រាស់ តារាងអាត្រា និងនាមការបញ្ជីពន្ធគយ ប្រព័ន្ធមុខទំនិញ និងប្រព័ន្ធលេខកូដទំនិញ និងមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម ដូចជា : ការប្រើប្រាស់លេខកូដទំនិញលើសពី ៦ខ្ទង់ ការទទួលយកអនុវត្តប្រព័ន្ធចុះសំរុងគ្នា (H.S) នៅតាមការធ្វើសេចក្តីសម្រេច និងការធ្វើវិសោធនកម្ម

ទាំងឡាយ ដែលធ្វើឡើងដោយក្រុមប្រឹក្សាអង្គការគយពិភពលោក ។ការចុះនាមការ(សារបានឬបញ្ជីរាយឈ្មោះទំនិញ)នៃប្រពន្ធ័ចុះសំរុងគ្នា ។ ល ។

៩. ពិធីសារទី ១ :ការកំណត់ផ្លូវ និងផ្លូវរបៀង ព្រមទាំងចំណុចចេញ-ចូល(ឆ្លងកាត់ព្រំដែន)

ពិធីសារទិ១នេះមាន ១២មាត្រា(និងមានឯកសារភ្ជាប់ : បញ្ជីនៃផ្លូវរបៀង,ផ្លូវថ្នល់និងច្រកឆ្លងកាត់ ព្រំដែន និងផែនទីភ្ជាប់ ទំហំ A4 (A4-format) ដែលពាក់ព័ន្ធទៅនឹង ការកំណត់ផ្លូវថ្នល់ និងផ្លូវមេ ព្រមទាំងចំណុចចេញ-ចូល និងប៉ុស្តិត្រួតពិនិត្យច្រកព្រំដែន និងមានខ្លឹមសារសំខាន់ៗ ដូចខាងក្រោម ដូចជា :

ការបើកបន្ថែម ច្រកឆ្លងកាត់ព្រំដែន និងផ្លូវផ្សេងៗទៀត : អាចធ្វើឡើងតាមរយៈអនុស្សារណៈនៃការយោគយល់គ្នា រវាងនិងក្នុងរង្វង់ភាគីចុះកិច្ចសន្យាមួយក្រុម ។ ការបើកបន្ថែមច្រកឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយបែបនេះ ត្រូវបានគេទទួលស្គាល់ដូចគ្នា ដូចច្រកឆ្លងកាត់ព្រំដែន ឬផ្លូវទាំងឡាយ ដែលបានលើកឡើង ជាលើកដំបូងនៅក្នុងពិធីសារនេះ និងត្រូវជូនដំណឹងទៅគណៈកម្មាធិការរួម អំពីការបើកបន្ថែម ហើយនឹងដាក់បញ្ចូលនៅក្នុងមាត្រា ១ នៃពិធីសារនេះ តាមរយៈការធ្វើវិសោធនកម្ម ។ល

១០. ឧបសម្ព័ន្ធទី ១ : ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់

ឧបសម្ព័ន្ធទី១នេះមាន ១២មាត្រា ពាក់ព័នទៅនឹងការចាត់ថ្នាក់ ប្រភេទទំនិញគ្រោះថ្នាក់ និយាមការ(ស្តង់ដារ) ជាការណែនាំចលនាឆ្លងកាត់ព្រំដែន នូវទំនិញគ្រោះថ្នាក់ ដែលស្របតាមឯកសារអាដេអ៊ែរ និង/ឬ បទប្បញ្ញត្តិជាមូដែលអង្គការសហប្រជាជាតិ ជាពិសេសទាក់ទងទៅនឹង :ការវេចខ្ចប់ និងការដាក់ផ្លាកសញ្ញាសំគាល់ទំនិញគ្រោះថ្នាក់, ការលាបពណ៌យានយន្ត ការលើកដាក់ រក្សាទុក និងការចងភ្ជាប់, ឯកសារ ដឹកជញ្ជូន និងសេចក្តីប្រកាស, ការហ្វឹកហាត់បណ្តុះបណ្តាលនាវិក និងការព្រមានប្រឆាំងទល់នឹងភ្លើងឆេះ និង/ ឬក៏ការ ផ្ទុកទាំងឡាយ ។ ល ។

១១. ឧបសម្ព័ន្ធទី ៩ :លក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់ប័ណ្ណអនុញ្ញាតដល់ប្រតិបត្តិករដឹកជញ្ជូន សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

ឧបសម្ព័ន្ធទី៩ នេះមាន ១៥មាត្រា ពាក់ព័ន្ធទៅនឹង សកម្មភាព ល័ក្ខខ័ណ និងតំរូវការទាំងឡាយ ដែលត្រូវបំពេញដោយប្រតិបត្តិករដឹកជញ្ជូន ដើម្បីធ្វើសកម្មភាពប្រតិបត្តិការដឹកជញ្ជូន ដូចជាមូលដ្ឋាននៃការជ្រើសរើស ការផ្តល់អជ្ញាប័ណ្ណ ការគ្រប់គ្រងនិងប្រសិទ្ធភាពនៃសហគ្រាស ការដកហូតអជ្ញាប័ណ្ណ លក្ខខ័ណ្ឌជាម្ចាស់កម្មសិទ្ធជាពលរដ្ឋនៃសហគ្រាសប្រតិបត្តិការដឹកជញ្ជូន តំរូវការកាន់កាប់ភាគហ៊ុនចំនួនច្រើនជាង៥០% និងដឹកនាំដោយពលរដ្ឋភាគច្រើននៃប្រទេសដើម ភាពអាចជឿទុកចិត្តបាន ការមិនធ្លាប់មានទទួលទោសទ័ណ្ឌធ្ងន់ធ្ងរណាមួយ ការដកហូតចេញពីឯកទេសជំនាញក្នុងការអនុវត្តន៏ការងារជាអ្នកដឹកជញ្ជូន ក៏ដូចជាការការដាក់ទណ្ឌកម្មក្នុងការប្រព្រឹត្តខុស ទៅនឹងការអនុវត្តច្បាប់ឬបទបញ្ញត្តិនៅក្នុងវិស័យដឹកជញ្ជូន ការប្រកាសអំពីការក្ស័យធន សមត្ថភាពអនុវត្តឯកសិទ្ធិ ឬក៏ការដោះស្រាយថវិកា នៃប្រតិបត្តិករដឹកជញ្ជូន ការធ្វើនិតិសម្បទាឡើងវិញ ។ល ។ ការធានាផ្ទៀងផ្ទាត់សមត្ថភាពរបស់ប្រតិបត្តិករដឹកជញ្ជូន ឱ្យស្របទៅតាម គោលការណ៍គ្រប់គ្រងសេដ្ឋកិច្ច ការផ្គត់ផ្គង់សេវាប្រកបដោយគុណភាព ការប្រកួតប្រជែងដោយគុណភាព តំលាភាព និងប្រតិបត្តិការដោយសុវត្ថិភាពនៃសហគ្រាសដឹកជញ្ជូន ជំនាញនិងបំណិនប្រសប់ នៅក្នុងវិស័យដូចជាចំណេះដឹងខាងផ្លូវច្បាប់ ការគ្រប់គ្រងប្រតិបត្តិការដឹកជញ្ជូន ដែលពាក់ព័ន្ធទៅដល់ការធ្វើជំនួញខាងដឹកជញ្ជូន និតិវិធីខាងហិរញ្ញវត្ថុ បទបញ្ញត្តិនៃតំលៃ ការធានារ៉ាប់រង អជ្ញាកណ្តាលនៃការដឹកជញ្ជូន បច្ចេកទេសគ្រប់គ្រងនិងការរកទីផ្សារ លក្ខខ័ណ្ឌនិងតំរូវការ លើការចូលទៅរកទីផ្សារ ការយល់ដឹងអំពីជំនាញ ឯកសារដឹកជញ្ជូន ការប្រយុទ្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ វិធានការបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការដឹកជញ្ជូន ឧ. ទំហំ និងទំងន់នៃយានយន្ត ជំរើសយានយន្ត ការថែទាំយានយន្ត ការផ្ទុកលើកដាក់ និងផ្ទេរយានយន្ត, ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ និងទំនិញងាយខូចរលួយ គោលការណ៍នៃការការពារបរិស្ថាន សុវត្ថិភាពចរាចការព្រមាន និងការសំរាលគ្រោះថ្នាក់ចរាចរ ។ល។ សមត្ថភាពផ្នែកហិរញ្ញវត្ថុដូចជាប្រសិទ្ធភាពនិងការបំពេញតារាងតុល្យភាព តារាងទ្រព្យសម្បត្តិ ឥណទាន គណនីពីធនាគារ- សមត្ថភាពទទួលបានឥណទានកំចី- លិខិតធានារ៉ាប់រងពីធនាគារ- ការធានារ៉ាប់រង លើការទទួលខុសត្រូវ និងត្រូវមានការធានារ៉ាប់រងនៃប្រតិបត្តិករលើកិច្ចសន្យា។

១២_ ឧបសម្ព័ន្ធទី ១៣ខ: លក្ខណៈវិនិច្ឆ័យសំរាប់ផ្តល់អជ្ញាប័ណ្ណអនុញ្ញាតដល់ប្រតិបត្តិករដឹកជញ្ជូនពហុរូបភាព សំរាប់ប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

ឧបសម្ព័ន្ធទី ១៣ខនេះមាន ១៥មាត្រា ពាក់ព័ន្ធទៅនឹងសកម្មភាព លក្ខខ័ណ្ឌ តំរូវការ និងការអនុវត្តន៏លើការដឹកជញ្ជូនពហុភាពជាអន្តរជាតិដូចជា:សិទ្ធិ(ច្បាប់)ជាមូលដ្ឋាន ក្នុងការទទួលឬដកហូតអជ្ញាប័ណ្ណ និង/ឬការចុះបញ្ជី លក្ខខ័ណ្ឌច្បាប់និងបទបញ្ញត្តិជាតំរូវការទាំងឡាយផ្សេងទៀត ដោយគោរពទៅតាមសមត្ថភាពជំនាញ ប្រសិទ្ធភាព និងទំនុកចិត្តក្នុងវិជ្ជាជីវៈ ឬអាជីវកម្ម ការប្រកាសខ្លួនមិនធ្លាប់មានទទួលទោសទ័ណ្ឌធ្ងន់ធ្ងរណាមួយ ការដកហូតចេញពីឯកទេសជំនាញ ការដាក់ទណ្ឌកម្មក្នុងការប្រព្រឹត្តខុសទៅនឹងការអនុវត្តច្បាប់ ឬបទបញ្ញត្តិនៅក្នុងវិស័យដឹកជញ្ជូនផ្លូវគោក ការប្រកាសអំពីការក្ស័យធន សមត្ថភាពអនុវត្ត ឯកសិទ្ធិ ឬក៏ការដោះស្រាយថវិកា ការធ្វើនីតិសម្បទា ឡើងវិញ។ល។ សមត្ថភាពជំនាញក្នុងការយល់ដឹងគោលការណ៏គ្រប់គ្រងសេដ្ឋកិច្ចការផ្គត់ផ្គង់សេវាប្រកបដោយគុណភាព ការប្រកួតប្រជែងដោយតំលាភាព ប្រតិបត្តិការដោយសុវត្ថិភាពនៃសហគ្រាសដឹកជញ្ជូន ជំនាញប៉ិនប្រសប់នៅក្នុងវិស័យ ចំណេះដឹងខាងផ្លូវច្បាប់ (ឧ.កិច្ចសន្យាដឹកជញ្ជូន និងការទទួលខុសត្រូវ(ធានារ៉ាប់រង)របស់អ្នកដឹកជញ្ជូន កិច្ចសន្យាដឹកជញ្ជូនពហុភាព ច្បាប់សហគ្រាស ច្បាប់គណនេយ្យ ច្បាប់ពលកម្ម ច្បាប់សារពើពន្ធ ។ល។)ការគ្រប់គ្រងប្រតិបត្តិការ ដឹកជញ្ជូន(ឧ.ការគណនាតំលៃ និងថ្លៃដឹក ជញ្ជូន ការបង់ចំណាយ និងនិតិវិធីខាងហិរញ្ញវត្ថុ ការកែសំរួលតំលៃ ការធានារ៉ាប់រង អជ្ញាកណ្តាលនៃការដឹកជញ្ជូន បច្ចេកទេស គ្រប់គ្រង និងការរកទីផ្សារ) លក្ខខ័ណ្ឌ និងតំរូវការ លើការចូលទៅរកទីផ្សារ (ឧ. ការយល់ដឹងអំពីជំនាញឯកសារដឹកជញ្ជូន ការប្រកួតប្រជែងដោយស្មោះត្រង់ ការប្រយុទ្ធប្រឆាំងនឹងការលក់បង្ខូចថ្លៃ វិធានការបច្ចេកទេសដែលពាក់ព័ន្ធទៅនឹងប្រតិបត្តិការដឹកជញ្ជូន (ឧ. ទំហំ និងទំងន់នៃយានយន្ត ឬនាវា ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ និងទំនិញងាយខូចរលួយ គោលការណ៏នៃការការពារបរិស្ថាន សំរាប់ការដឹកជញ្ជូន វិធានការសំរាប់សុវត្ថិភាព និងសន្តិសុខ ។ល។ សមត្ថភាពផ្នែកហិរញ្ញវត្ថុ ប្រសិទ្ធភាពនិងការបំពេញ • តារាងតុល្យភាពរបស់ប្រតិបត្តិករដឹកជញ្ជូន តារាងទ្រព្យសម្បត្តិ ឥណទាន គណនីពីធនាគារ សមត្ថភាពទទួលបានឥណទានកំចី លិខិតធានារ៉ាប់រងពីធនាគារ ការធានារ៉ាប់រង លើការទទួលខុសត្រូវ និងត្រូវមានការធានារ៉ាប់រងនៃប្រតិបត្តិករលើកិច្ចសន្យា ។ប្រតិបត្តិករដឹកជញ្ជូនពហុភាព ត្រូវរក្សាទុកទ្រព្យសម្បត្តិអប្បរមា ដែលមានតំលៃស្មើនឹង៨០ ០០០អែសដេអ៊ែរ (Special Drawing Right) ឬផ្តល់ការធានារ៉ាប់រងណាមួយដែលមានតំលៃស្មើ។

១៣_ ឧបសម្ព័ន្ធទី ១៦ :លក្ខណៈវិនិច្ឆ័យសំរាប់ការផ្តល់ប័ណ្ណបើកបរ

ឧបសម្ព័ន្ធទី១៦ នេះមាន ១៣មាត្រា ពាក់ព័ន្ធទៅនឹងតំរូវការ ល័ក្ខខ័ណ្ឌ និងការអនុវត្តន៏ក្នុងការទទួលស្គាល់ទៅវិញទៅមកនូវប័ណ្ណបើកបរក្នុងស្រុក រវាងភាគីចុះកិច្ចសន្យា សុពលភាព និងអត្តិភាពប័ណ្ណបើកបរ ការភ្ជាប់ការបកប្រែបញ្ជាក់អំពីប័ណ្ណបើកបរ ចំណុចពិសេសនៃប័ណ្ណបើកបរ ទំនាក់ទំនងនិងការជូនដំណឹងគ្នាទៅវិញទៅមក ទៅកាន់អជ្ញាធរ ដែលចេញប័ណ្ណបើកបររៀង១ខ្លួន នូវអ្វីដែលមានការផ្លាស់ប្តូរ លើប័ណ្ណ។ល។

មានមាត្រាចាំបាច់មួយចំនួន ដែលស្ថិតនៅក្នុងអន្តរបញ្ញត្តិសំរាប់អនុវត្ត រាល់ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយខាងលើ(*ឧបសម្ព័ន្ធ១ ២.៤.៧.៩. ១១.១២. ១៣ក .១៣ខ.១៥ .១៦ និងពិធីសារទី១*) ដូចជា : ការធ្វើវិសោធនកម្ម ការផ្តល់សច្ចាប័ន និងការយល់ព្រម ការចូលជាធរមាន ការកែសំរួលច្បាប់ជាតិ ការដាក់លក្ខខ័ណ្ឌ ការព្យួរទុកនៃឧបសម្ព័ន្ធ ទំនាក់ទំនងជាមួយកិច្ចព្រមព្រៀងមេ តំលៃឬទំនាក់ទំនង រវាងឬជាមួយឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធ ការដោះស្រាយជំលោះ ការប្រកាសបដិសេធ ។ល។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសាធារណការ និងដឹកជញ្ជូន

ឧបសម្ព័ន្ធ និងពិធីសារ

១-ឧបសម្ព័ន្ធទី១ :ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់
២-ឧបសម្ព័ន្ធទី២ :ការចុះបញ្ជីយានយន្ត ទៅក្នុងចរាចរអន្តរជាតិ
៣-ឧបសម្ព័ន្ធទី៤ :ការសំរបសំរួលបែបបទឆ្លងកាត់ព្រំដែន
៤-ឧបសម្ព័ន្ធទី៧ :បទបញ្ញត្តិចរាចរតាមផ្លូវថ្នល់ និងផ្លាកសញ្ញា
៥-ឧបសម្ព័ន្ធទី៩ :លក្ខណៈវិនិច្ឆ័យសំរាប់ការចេញអាជ្ញាប័ណ្ណឱ្យប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ព្រំដែន
៦-ឧបសម្ព័ន្ធទី១១:បទដ្ឋាន ឬមាត្រដ្ឋាន(ស្តង់ដារ) និងលក្ខណៈបច្ចេកទេស
៧-ឧបសម្ព័ន្ធទី១២:សេវា និងសម្បទា(ឬមធ្យោបាយ)សំរាប់ការឆ្លងកាត់ និងការឆ្លងព្រំដែន
៨-ឧបសម្ព័ន្ធទី១៣អា:របបគ្រប់គ្រងការទទួលខុសត្រូវ អ្នកដឹកជញ្ជូនពហុភាព
៩-ឧបសម្ព័ន្ធទី១៣បេៈ លក្ខណៈវិនិច្ឆ័យសំរាប់ការចេញអាជ្ញាប័ណ្ណឱ្យប្រតិបត្តិករដឹកជញ្ជូនពហុភាព
១០-ឧបសម្ព័ន្ធទី១៥ៈ ប្រព័ន្ធចាត់ថ្នាក់ទំនិញ
១១-ឧបសម្ព័ន្ធទី១៦ៈ លក្ខណៈវិនិច្ឆ័យសំរាប់ការចេញប័ណ្ណបើកបរ
១២-ពិធីសារទី១:ការកំណត់ផ្លូវ និងផ្លូវបៀង ព្រមទាំងចំណុចចេញ-ចូល(ការឆ្លងកាត់ព្រំដែន)
១៣-វិសោធនកម្មមាត្រាទី១៧ នៃកិច្ចព្រមព្រៀង GMS សំរួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

សំរាប់អនុវត្តកិច្ចព្រមព្រៀង GMS

ស្តីពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

នាយកដ្ឋានផែនការ

សីហា ឆ្នាំ ២០០៦

ឧបសម្ព័ន្ធទី ៦

ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាត់ថា ឧបសម្ព័ន្ធ)

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាព មីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា ភាគីចុះកិច្ចសន្យា)

ដោយយោងទៅលើ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាដំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន , ដែលបានយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី ហើយបានធ្វើវិសោធនកម្មនៅភ្នំពេញថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៤តទៅហៅកាត់ថា កិច្ចព្រមព្រៀង

ដោយយោងទៅលើ មាត្រាទី ៣(ហ) និង(អ៊ិន) នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅលើ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅលើ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០, កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្កើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសារ របស់វា ក្នុងឆ្នាំ ២០០៥ និង

ដោយយោងទៅលើ មាត្រាទី៣(អ៊ី) និង១០(អា) នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្តល់តាមរយៈឧបសម្ព័ន្ធនេះ នូវការរៀបចំលំអិត ខាងបច្ចេកទេស

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១ .- និយមន័យ

ពាក្យថា " ទំនិញគ្រោះថ្នាក់ " មានន័យថា សារធាតុ និង វត្ថុធាតុទាំងឡាយ ដែលមានឥទ្ធពលទៅលើ បរិស្ថាន សុខភាព សុវត្ថិភាព និងសន្តិសុខជាតិ ។

មាត្រា ២ .- ការចាត់ថ្នាក់នូវទំនិញគ្រោះថ្នាក់

ក-ទំនិញគ្រោះថ្នាក់ទាំងឡាយ ត្រូវបានគេបែងចែកទៅតាមចំណាត់ថ្នាក់ ឬផ្នែកដូចខាងក្រោម :

ចំណាត់ថ្នាក់ទី ១ : គ្រឿងផ្ទុះ (Explosives)

ចំណាត់ថ្នាក់ទី ២ : ឧស្ម័ន (Gases)
ផ្នែកទី ២-១ : ឧស្ម័នអាចឆេះ (Flammable Gases)
ផ្នែកទី ២-២ : ឧស្ម័នដែលមិនអាចឆេះ-មិនមានជាតិពុល (Non-flammable, Non-toxic gases)
ផ្នែកទី ២-៣ : ឧស្ម័នពុល (Toxic gases)

ចំណាត់ថ្នាក់ទី ៣ : វត្ថុរាវអាចឆេះ និងវត្ថុរាវដែលងាយនឹងផ្ទុះ (Flammable Liquids and desensitized explosives)

ចំណាត់ថ្នាក់ទី ៤ : ផ្នែកទី ៤-១ : វត្ថុរឹងអាចឆេះ, សារធាតុដែលបញ្ចេញវិទ្យុសកម្មដោយឯកឯង និងវត្ថុធាតុរឹងដែលងាយបង្កឱ្យផ្ទុះ (Flammable Solids self-reactive substances and solid desensitized explosive)

ផ្នែកទី ៤-២ : សារធាតុដែលអាចមានចំហេះដោយឯកឯង (Substances liable to spontaneous combustion)

ផ្នែកទី ៤-៣ : សារធាតុទាំងឡាយដែលមានប្រតិកម្មជាមួយទឹកអាចបញ្ចេញឧស្ម័នឆេះ (Substances which in contact with water emit flammable gases)

ចំណាត់ថ្នាក់ទី ៥ : ផ្នែកទី ៥-១ : សារធាតុឌីអុកស៊ីត (Oxidizing substances)
ផ្នែកទី ៥-២ : សរីរាង្គពឺរ៉ុកស៊ីដ (Organic peroxide)

ចំណាត់ថ្នាក់ទី ៦ : ផ្នែកទី ៦-១ : សារធាតុពុល (Toxic substances)
ផ្នែកទី ៦-២ : សារធាតុឆ្លង (Infectious substances)

ចំណាត់ថ្នាក់ទី ៧ : គ្រឿងវិទ្យុសកម្ម (Radioactive material)

ចំណាត់ថ្នាក់ទី ៨ : សារធាតុដែលស៊ី ឬ កាត់ (អាស៊ីត) (Corrosive substances)

ចំណាត់ថ្នាក់ទី ៩ : សារធាតុ និងអង្គធាតុគ្រោះថ្នាក់ផ្សេងទៀត (Miscellaneous dangerous substances and articles)

ខ- ការចាត់ថ្នាក់ទំនិញគ្រោះថ្នាក់ ទៅតាមប្រភេទចំណាត់ថ្នាក់ និងផ្នែកដូចខាងលើ ត្រូវធ្វើឡើងស្របទៅតាម ផ្នែកទី ២ នៃអនុសាសន៍របស់អង្គការសហប្រជាជាតិ ស្តីអំពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ ឬក៏ម៉ូដែល បទប្បញ្ញត្តិ (ម៉ូដែលជាបទ ប្បញ្ញត្តិអង្គការសហប្រជាជាតិ) និង ឬ កិច្ចព្រមព្រៀងអឺរ៉ុប ពាក់ព័ន្ធទៅនឹងការ ដឹកជញ្ជូន ទំនិញគ្រោះថ្នាក់ នៅតាមផ្លូវថ្នល់ (អាដេអ៊ែរ) ដែលចុះហត្ថលេខានៅទីក្រុងហ្សឺណែវ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ ១៩៥៧ រាប់ទាំង ការធ្វើវិសោធនកម្មក្រោយៗមក និងទៅខាងមុខ ផងដែរ ។

មាត្រា ៣ .. បទដ្ឋាន(ស្តង់ដារ) ជាការណែនាំ ចលនាឆ្លងកាត់ព្រំដែន នូវទំនិញគ្រោះថ្នាក់

ប្រសិនបើ ភាគីចុះសន្យា អនុញ្ញាត ទៅតាមមូលដ្ឋាន ពីមួយករណីទៅមួយករណី ការធ្វើចរាចរឆ្លងកាត់ ព្រំដែន នូវទំនិញដូចបានកំណត់ខាងលើ ទាមទារការអនុវត្តយ៉ាងពេញលេញនូវវិធានការទាំងឡាយ ដែលស្ថិតនៅក្រោម អាដេអ៊ែរ និង/ឬ បទប្បញ្ញត្តិជាម៉ូដែលអង្គការសហប្រជាជាតិ ជាពិសេសទាក់ទងទៅនឹង :

ក- ការវេចខ្ចប់ និងការដាក់ផ្លាកសញ្ញាសំគាល់ទំនិញគ្រោះថ្នាក់

ខ- ការលាបពណ៌យានយន្ត ការលើកដាក់ រក្សាទុក និងការចងភ្ជាប់

គ- ឯកសារដឹកជញ្ជូន និងសេចក្តីប្រកាស

ឃ- ការហ្វឹកហាត់បណ្តុះបណ្តាលនាវិក

ង- ការព្រមានប្រឆាំងទល់នឹងភ្លើងឆេះ និង/ ឬក៏ការផ្ទុកទាំងឡាយ

មាត្រា ៤.. ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណកម្មាធិការរួម។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន្ទ ពីភាគីចុះកិច្ចសន្យាទាំងអស់ ។

មាត្រា ៥.. ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

មាត្រា ៦.. ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន ។

មាត្រា ៧.. ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្រប ទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ ។

មាត្រា ៨.. ការដាក់លក្ខខ័ណ្ឌ

ការដាក់លក្ខខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ៩.. ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន-នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការកើតជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន ។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀត ភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណា ដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ ។

មាត្រា ១០.. ទំនាក់ទំនង ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះ ។ នៅក្នុងករណីដែល វិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយក

ជាបានការ ។ នៅក្នុងករណីដែល វិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬ ពិធីសារផ្សេងទៀតនោះ វិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង។

មាត្រា ១១.. ការដោះស្រាយជំលោះ

ជំលោះរវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា នៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវសុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម ។

មាត្រា ១២.. ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធដាច់ដោយឡែក ចេញអំពី កិច្ចព្រមព្រៀងបានទេ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតពីអង្គាចរៀង១ខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ វៀងច័ន្ទ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម **យឹម ឆាយលី** ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីទទួលបន្ទុកសហប្រតិបត្តិការមហាអនុតំបន់មេគង្គ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម **លោច ស៊ាចយន់** អនុរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ឯកឧត្តម **សំម៉ាដ ផុលសេនា** អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម **ស៊ូ ថា** រដ្ឋមន្ត្រីអភិវឌ្ឍផែនការ និងសេដ្ឋកិច្ចជាតិ

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៏
ឯកឧត្តម **និភន ចំណុច** អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម **ចាន់ ហ្វ៊ីនខៀន** អនុរដ្ឋមន្ត្រី ផែនការ និងវិនិយោគ

ANNEX 1: CARRIAGE OF DANGEROUS GOODS

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as " the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed at Vientiane on 26 November 1999, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China at Phnom Penh on 3 November 2002, and acceded to by the Union of Myanmar at Dali City on 19 September 2003, and amended at Phnom Penh on 30 April 2004 (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 3(e) and 10(a) of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Article 1: Definition

The term "Dangerous Goods" shall mean those substances and articles, which may affect the interest of environment, health, safety, and national security.

Annex 1: Carriage of Dangerous Goods

Article 2: Classification

(a) Dangerous Goods shall be divided into the following classes/divisions:

Class 1: Explosives

Class 2: Gases

Division 2.1: Flammable gases
Division 2.2: Non-flammable, non-toxic gases
Division 2.3: Toxic gases

Class 3: Flammable liquids and liquid desensitized explosives

Class 4:

Division 4.1: Flammable solids, self-reactive substances, and solid desensitised explosives
Division 4.2: Substances liable to spontaneous combustion
Division 4.3: Substances which in contact with water emit flammable gases

Class 5:

Division 5.1: Oxidizing substances
Division 5.2: Organic peroxides

Class 6:

Division 6.1: Toxic substances
Division 6.2: Infectious substances

Class 7: Radioactive material

Class 8: Corrosive substances

Class 9: Miscellaneous dangerous substances and articles

(b) Assignment of dangerous goods to the above classes/divisions shall be made consistent with the substantive provisions of Part 2 of the United Nations Recommendations on the Transport of Dangerous Goods/Model Regulations (UN Model Regulations), and/or the European Agreement Concerning the International Carriage of Dangerous Goods by Road (ADR), signed in Geneva on 30 September 1957, including subsequent and future amendments thereto.

Article 3: Standards Governing the Cross-Border Movement of Dangerous Goods

If the Contracting Parties permit on a case-by-case basis the cross-border movement of Dangerous Goods as defined above, they should require the full application of the measures under the ADR and/or the UN Model Regulations in particular relating to:

(a) packing and labeling of dangerous goods;
(b) vehicle marking, handling, stowing, and lashing;
(c) transport documentation and declaration;
(d) crew training; and
(e) precaution against fire and/or explosions.

Article 4: Amendment

Any Contracting Party may propose amendments to the Annex via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 5: Ratification or Acceptance

The Annex is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Annex, if any.

Article 6: Entry into Force

The Annex will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Annex, if any.

Article 7: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Annex.

Article 8: Reservations

No reservation to the Annex shall be permitted.

Article 9: Suspension of the Annex

Each Contracting Party may temporarily suspend wholly or partly the application of the Annex with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Article 10: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Annex cannot depart from or be contrary to these principles. In case of incompatibility between the Annex and the Agreement, the latter shall prevail. In case of incompatibility between the Annex and another annex or protocol, such incompatibility shall be interpreted in light of the Agreement.

Article 11: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Annex shall be settled directly or by amicable negotiation in the Joint Committee.

Article 12: Denunciation

Once entered into force, the Annex cannot be denounced separately from the Agreement.

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Vientiane on 16 December 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

....

His Excellency Khy Tainglim
Senior Minister and Minister In-charge of GMS

For the Government of the People's Republic of China

....

His Excellency Liao Xiaojun
Vice Minister of Finance

For the Government of the Lao People's Democratic Republic

....

His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

....

His Excellency Soe Tha
Minister for National Planning and Economic Development

For the Government of the Kingdom of Thailand

....

His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

....

His Excellency Tran Dinh Khien
Vice Minister of Planning and Investment

ឧបសម្ព័ន្ធទី ២

ការចុះបញ្ជីយានយន្ត នៅក្នុងចរាចរណ៍អន្តរជាតិ

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍

និងសាធារណរដ្ឋសង្គមនិយមវៀតណាម

ស្ដីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន

(តទៅហៅកាត់ថា "ឧបសម្ព័ន្ធ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា "ភាគីចុះកិច្ចសន្យា")

ដោយយោងទៅដល់ កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្ដីអំពីការសំរបសំរួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាដំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាំងហ្គូន , ដែលបានយល់ព្រមចូលដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាំងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០០១ បានយល់ព្រមចូលដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា "កិច្ចព្រមព្រៀង"

ដោយយោងទៅដល់មាត្រាទី ៣(ហេ)និង(អិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅដល់ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្ដល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅដល់ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០, កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទី១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសារ របស់វា ក្នុងឆ្នាំ ២០០៥ និង

ដោយយោងទៅដល់ មាត្រាទី៣(ញ) និងទី១២ នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្ដល់តាមរយៈឧបសម្ព័ន្ធនេះ នូវការរៀបចំលំអិត ខាងបច្ចេកទេស

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១ .. ប្រភេទ នៃយានយន្ត

យានយន្តមួយគ្រឿង គឺជាយានយន្តដើរដោយថាមពលមួយ ដែលជាធម្មតាប្រើប្រាស់សំរាប់ដឹកជញ្ជូនពលរដ្ឋ ឬទំនិញតាមផ្លូវថ្នល់ ។ វារាប់បញ្ចូលផងដែរ នូវយានយន្តរឹងជាប់គ្នានដំណ (ឬរថយន្តកាំមីញ៉ុង) យានយន្តមានតំណ (ជាក្បាលសណ្តោងដែលអូសទាញស៊ីមីរ៉ឺម៉កមួយ) និងស៊ីមីរ៉ឺម៉ក(យានត្រូវបានគេអូស ឬសណ្តោងដោយយានយន្តមួយនៅក្នុងស្ថានភាពដែលផ្នែកនៃរ៉ឺម៉កត្រូវបានគេផ្គត់ភ្ជាប់ទៅនឹងក្បាលសណ្តោង ហើយផ្នែកដែលទ្រទ្រង់ទំងន់នៃរ៉ឺម៉ក និងបន្ទុករបស់វា ត្រូវគេគិតបញ្ចូលជាទំងន់ និងបន្ទុករបស់យានយន្តទាំងមូល)។ ទោះជាយ៉ាងណាក៏ដោយ វាមិនគ្របដណ្តប់ទៅលើយានយន្តទាំងឡាយណា ដែលគ្រាន់តែប្រើប្រាស់ ម្តងម្កាលក្នុងការដឹកជញ្ជូនមនុស្ស ឬទំនិញតាមផ្លូវថ្នល់ ឬសំរាប់អូសទាញនៅលើផ្លូវថ្នល់ ដូចជា ត្រាក់ទ័រកសិកម្ម ឬមធ្យោបាយគ្រឿងចក្រមៅការសាងសង់ផ្លូវថ្នល់ទាំងឡាយ ។ វាក៏មិនគ្របដណ្តប់ផងដែរ ទៅលើយានបថ ឬរថដែលរត់នៅលើផ្លូវដែកទាំងឡាយ សូឡិច-ម៉ូតូ (ទោចក្រយានយន្ត)។ គំនូសដ្យាក្រាមមួយនៃយានយន្តទាំងឡាយ ដែលបញ្ជាក់នៅក្នុងឧបសម្ព័ន្ធនេះ មាននៅក្នុងឯកសារភ្ជាប់។

មាត្រា ២ .. ករណីកិច្ចនៃការចុះបញ្ជី

យានយន្តទាំងឡាយ ស៊ីមី-រ៉ឺម៉កទាំងឡាយដែលប្រើប្រាស់ក្នុងចរាចរឆ្លងកាត់ព្រំដែន ត្រូវចុះបញ្ជីនៅឯប្រទេសដើមរបស់ខ្លួន ទៅតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងឧបសម្ព័ន្ធនេះ ។

មាត្រា ៣ .. ការប្រើប្រាស់ភាសា និងតួអក្សរ

នៅក្នុងសញ្ញាសំគាល់ម៉ាកយានយន្ត ,វិញ្ញាបនប័ត្រចុះបញ្ជីយានយន្ត និងផ្លាកលេខចុះបញ្ជីយានយន្ត ចំណុចពិសេសទាំងឡាយត្រូវសរសេរជាភាសាអង់គ្លេស(ជាតួអក្សរពុម្ពធំ ឬតួអក្សរពុម្ពតូច) និងជាលេខអារ៉ាប់។ ការប្រើប្រាស់សំណេរជាភាសាអង់គ្លេស និងជាលេខអារ៉ាប់ មិនបានហាមឃាត់ដល់ការសរសេរឡើងវិញ នូវចំណុចទាំងឡាយ ដោយការប្រើប្រាស់ស្របគ្នា នូវភាសា និងតួអក្សរជាតិនោះទេ។

មាត្រា ៤ .. សញ្ញាសំគាល់យានយន្ត(ម៉ាក)

(ក) -រាល់យានយន្ត ទាំងឡាយ នៅក្នុងចរាចរឆ្លងកាត់ព្រំដែន ត្រូវមានសញ្ញាសំគាល់យានយន្ត(ម៉ាក) ដូចខាងក្រោម :

(១) ឈ្មោះ ឬ និមិត្តសញ្ញាពាណិជ្ជកម្ម នៃរោងចក្រផលិតយានយន្ត

(២) នៅលើសាក់ស៊ី ឬករណីអវត្តមានមិនមានសាក់ស៊ី នៅលើតួយានត្រូវមានលេខផលិតផល របស់រោងចក្រ ឬលេខស៊េរីរបស់យានយន្ត និង

(៣) នៅលើគ្រឿងម៉ាស៊ីន ។ ត្រូវមានលេខម៉ាស៊ីន ប្រសិនបើលេខដូចនេះត្រូវបានគេដាក់ជំនួសពីលើវាដោយម៉ាកសំគាល់ (មិនចាំបាច់សំរាប់រ៉ឺម៉ក ឬស៊ីមី-រ៉ឺម៉កទេ) ។

(ខ) - សញ្ញាសំគាល់ទាំងនេះត្រូវដាក់ក្នុងស្ថានភាពងាយអាចចូលទៅបាន និងងាយមើលឃើញ ។ ជាបន្ថែម សញ្ញាទាំងនេះមិនអាចងាយស្រួលក្នុងការកោសលុបកែប្រែ ឬ លើកចេញបានទេ ។

មាត្រា ៥ .. វិញ្ញាបនប័ត្រ នៃការចុះបញ្ជី (ប័ណ្ណចុះបញ្ជី ឬប័ណ្ណសំគាល់យានយន្ត)

(ក) - រាល់យានយន្តទាំងឡាយ នៅក្នុងចរាចរឆ្លងកាត់ព្រំដែន ត្រូវយកតាមខ្លួន ប័ណ្ណនៃការចុះបញ្ជី ដែលមានសុពលភាព ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ច នៃប្រទេសដើមរបស់ខ្លួន ។

(ខ) ប័ណ្ណចុះបញ្ជីត្រូវមាន លក្ខណៈពិសេសដូចតទៅ :

១. **ពត៌មានជាមូលដ្ឋាន :**

១.១ ចំណងជើងឯកសារ : ប័ណ្ណចុះបញ្ជីយានយន្ត
១.២ ឈ្មោះ(និងសញ្ញាឡូហ្គូ) នៃអាជ្ញាធរដែលចេញឱ្យ ប័ណ្ណចុះបញ្ជីយានយន្ត
១.៣ អាស័យដ្ឋាន និងទិន្នន័យសំរាប់ទាក់ទង (ណាមួយក៏បាន) នៃអាជ្ញាធរដែលចេញឱ្យប័ណ្ណចុះបញ្ជីយានយន្ត
១.៤ ឈ្មោះប្រទេស(តាមរយៈសញ្ញាសំគាល់ឈ្មោះប្រទេស)នៃអាជ្ញាធរដែលចេញឱ្យប័ណ្ណចុះបញ្ជីយានយន្ត
១.៥ លក្ខណៈសំគាល់ខាងផ្លូវច្បាប់(សៀល/ឃ្លុំត្រា , ហត្ថលេខា)
១.៦ កាលបរិច្ឆេទ នៃការចេញឱ្យប័ណ្ណចុះបញ្ជីយានយន្ត

២. ចំណុចពិសេសៗ នៃការចុះបញ្ជី
២.១ ផ្លាកលេខអនុញ្ញាត ឬលេខចុះបញ្ជី
២.២ សញ្ញាសំគាល់លក្ខណៈជាតិ ឬឈ្មោះប្រទេស នៃប្រទេសដើមចុះបញ្ជី
២.៣ កាលបរិច្ឆេទនៃការចុះបញ្ជីលើកទី១
២.៤ រយៈពេលមានសុពលភាព ប្រសិនបើមានការកំណត់

៣. ចំណុចពិសេសៗ នៃម្ចាស់ ឬអ្នកកាន់ប័ណ្ណចុះបញ្ជី
៣.១ ឈ្មោះពេញលេញ
៣.២ អស័យដ្ឋាន

៤. ចំណុចពិសេសៗ នៃយានយន្ត :
៤.១ ប្រភេទ: រថយន្តកាមីញ៉ុង ប៊ីស រថយន្តទេសចរណ៍ ។ល។
៤.២ តួយានយន្ត :
៤.២.១ ផ្លាកសញ្ញាក្រុមហ៊ុន ឬផ្លាកសញ្ញាពាណិជ្ជកម្ម
៤.២.២ ម៉ូដែល ឬកូដ (ប្រសិនបើមាន)
៤.២.៣ ពណ៌ (កូដ RAL)
៤.២.៤ ឆ្នាំផលិត (ប្រសិនបើមាន)
៤.២.៥ លេខស៊េរីរបស់សាក់ស៊ី
៤.២.៦ ចំនួនភ្លៅ
៤.២.៧ ទំងន់ទទេរ(តារ) (សំរាប់កាម៉ុង និងប៊ីស) (ការបាញ់ថ្នាំលាបជាពតិមាននៅលើតួយានយន្ត កាម៉ុង ឬប៊ីសអាចជ្រើសរើសបាន) ។
៤.២.៨ ទំងន់សរុប(កាម៉ុង) ឬសមត្ថភាពកៅអី(ប៊ីស) (ការបាញ់ថ្នាំលាបជាពតិមាននៅលើតួយានយន្ត កាម៉ុង ឬប៊ីសអាចជ្រើសរើសបាន)
៤.៣ តួម៉ាស៊ីន
៤.៣.១ ផ្លាកសញ្ញាក្រុមហ៊ុន(ប្រសិនបើផ្សេងខុសពីតួយាន)
៤.៣.២ ចំនួនពីស្តុង
៤.៣.៣ សមត្ថភាព
៤.៣.៤ កំលាំងជាសេស
៤.៣.៥ លេខរៀងស៊េរី

មាត្រា ៦ .. ផ្លាកលេខចុះបញ្ជី

រាល់យានយន្តទាំងឡាយ នៅក្នុងចរាចរឆ្លងកាត់ព្រំដែន ត្រូវពាក់បង្ហាញលេខចុះបញ្ជីរបស់ខ្លួន នៅលើផ្លាកពិសេសបញ្ឈរាបស្មើមួយ(ឬច្រើន) ពាក់ជាប់នៅខាងមុខ និងខាងក្រោយយានយន្ត នៅចំទីតាំង ត្រឹមត្រូវមួយ ដែលមានជ្រុង ឬមុំត្រឹម កែងទៅនឹងផ្ទៃរាបមេដ្យានផ្តេកបណ្តោយរបស់យានយន្ត ដែលអាចឱ្យគេមើលឃើញច្បាស់នៅរយៈចំងាយមួយ ពី ៣៥-៤០ម៉ែត្រ។ ផ្ទៃនៃផ្លាកលេខអាចធ្វើឡើង អំពីវត្ថុធាតុចាំងផ្លាតពន្លឺ។ ស៊ីមី-រ៉ឺម៉កទាំងឡាយ ត្រូវពាក់បង្ហាញ លេខចុះបញ្ជី យ៉ាងហោចណាស់ នៅផ្នែកខាងក្រោយនៃយានយន្ត។

មាត្រា ៧ ._ សញ្ញាសំគាល់លក្ខណៈជាតិ

(ក) បន្ថែមពីលើលេខចុះបញ្ជី រាល់យានយន្តដែលធ្វើចរាចរឆ្លងកាត់ព្រំដែន ត្រូវពាក់បង្ហាញនៅផ្នែកខាងក្រោយយានយន្ត នូវសញ្ញាសំគាល់លក្ខណៈនៃប្រទេសដែលបានចុះបញ្ជី ។ សញ្ញាសំគាល់លក្ខណៈនេះត្រូវមានពី០១ ទៅ០៣ តួអក្សរ ជាតួអក្សរធំនៃអក្សរឡាតាំង យ៉ាងហោចណាស់ក៏មានកំពស់ ០.០៨ ម និងមានទទឹងស្នាមគំនូស នៃតួអក្សរ យ៉ាងហោចណាស់ ០.០១ម ។ អក្សរត្រូវលាបព័ណ៌ខ្មៅនៅពីលើផ្ទៃព័ណ៌សពីខាងក្រោយ ដែលមានរាងសណ្ឋានជាពង ក្រពើ (អេលីប) ហើយដែលខ្សែទ្រូងធំស្របទៅនឹងអ័ក្សផ្តេក។

(ខ) សញ្ញាសំគាល់លក្ខណៈជាតិមិនត្រូវបញ្ចូលគ្នាជាមួយលេខចុះបញ្ជីទេ ឬ ក៏មិនពាក់ភ្ជាប់នៅត្រង់កន្លែងណាមួយ ដែលវាអាចធ្វើអោយគេយល់ច្រលំ ជាមួយលេខចុះបញ្ជីនោះ ឬក៏ធ្វើអោយគេមិនអាចអានបាន ។

(គ) ការពាក់បង្ហាញត្រូវធ្វើឡើងដោយគោរពតាមលក្ខខ័ណ្ឌ នៃលេខចុះបញ្ជី ។

(ឃ) សញ្ញាសំគាល់លក្ខណៈ សំរាប់យានយន្តទាំងឡាយ នៃភាគីចុះកិច្ចសន្យានិមួយៗ ត្រូវធ្វើឡើងដូចតទៅ :

កម្ពុជា	:	KH
សាធារណរដ្ឋប្រជាមានិតចិន	:	CHN
សាធារណរដ្ឋ ប្រជាមានិតប្រជាធិបតេយ្យឡាវ	:	LAO
មីយ៉ាន់ម៉ា	:	MYA
ថៃឡង់ដ៏	:	T
វៀតណាម	:	VN

មាត្រា ៨ ._ ការទទួលស្គាល់ទៅវិញទៅមក

ភាគីចុះកិច្ចសន្យានិមួយៗ ត្រូវទទួលស្គាល់ទៅវិញទៅមកនូវផ្លាកលេខចុះបញ្ជីយានយន្ត ប័ណ្ណចុះបញ្ជីយានយន្ត និងវិញ្ញាបនប័ត្រត្រួតពិនិត្យយានយន្ត និង/ឬ កំណត់សំគាល់នៃការត្រួតពិនិត្យ ដែលចេញឱ្យដោយអជ្ញាធរមានសមត្ថកិច្ច (ទាំងឡាយ) នៃភាគីចុះកិច្ចសន្យាដទៃទៀត។

មាត្រា ៩._ ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណកម្មាធិការរួម។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន្ទ ពីភាគីចុះកិច្ចសន្យាទាំងអស់។

មាត្រា ១០._ ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ១១.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់វា នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធ។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ១២.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ។

មាត្រា ១៣.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លកខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ១៤.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការរីកវរជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀត ភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណា ដែល សភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ១៥.- ទំនាក់ទំនង ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះ ។ នៅក្នុងករណីដែល វិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ។ នៅក្នុងករណីដែល វិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា) រវាងឧបសម្ព័ន្ធ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង។

មាត្រា ១៦.- ទំនាក់ទំនង ជាមួយឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធ

ឯកសារភ្ជាប់ ត្រូវបង្កើតជាផ្នែករួមបញ្ចូលគ្នាមួយ ជាមួយឧបសម្ព័ន្ធ និងត្រូវមានតំលៃចូលរួមស្មើៗគ្នា ។

មាត្រា ១៧.- ការដោះស្រាយជំលោះ

ជំលោះរវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា នៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវសុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៍សន្តិវិធីតាមរយៈគណៈកម្មាធិការរួម។

មាត្រា ១៨.- ការប្រកាសបដិសេធ

នៅពេលណាដែលចូលជាធរមាន ឧបសម្ព័ន្ធមិនអាចឱ្យគេប្រកាសបដិសេធដាច់ដោយឡែក ចេញអំពីកិច្ចព្រមព្រៀងបានទេ

ឯកសារភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី២ : គំនូសជ្យាក្រាមនៃយានយន្តទាំងឡាយ ដែលមានចែងក្នុងឧបសម្ព័ន្ធទី២ ។

ដើម្បីជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម ដែលបានទទួលការអនុញ្ញាតពីអង្គការរៀងៗខ្លួន បានចុះហត្ថលេខាលើឧបសម្ព័ន្ធនេះ ។

ធ្វើនៅ ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៤ ជា០៦ ច្បាប់ដើម ជាភាសាអង់គ្លេស ។

ហត្ថលេខា :

តំណាងរាជរដ្ឋាភិបាលកម្ពុជា
ឯកឧត្តម ត្រាំ អ៊ីវតឹក រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន
ឯកឧត្តម ហ៊ូ ស៊ីហ៊ឺ អនុរដ្ឋមន្ត្រី គមនាគមន៍

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ
ឯកឧត្តម សំម៉ាដ ផុលសេនា អនុរដ្ឋមន្ត្រីគមនាគមន៍ ដឹកជញ្ជូន ប៉ុស្តិ៍ និងសំណង់

តំណាងរដ្ឋាភិបាលនៃសហភាពមីយ៉ាន់ម៉ា
ឯកឧត្តម ធូរ៉ា ថេខវីន អនុរដ្ឋមន្ត្រី ដឹកជញ្ជូនផ្លូវដែក

តំណាងរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍
ឯកឧត្តម នីភន ចំណុច អនុរដ្ឋមន្ត្រីដឹកជញ្ជូន

តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម
ឯកឧត្តម ផាំ ថេមិញ អនុរដ្ឋមន្ត្រីដឹកជញ្ជូន

សេចក្តីភ្ជាប់ទៅនឹងឧបសម្ព័ន្ធទី២

គំនូសជ្យាក្រោមនៃយានយន្ត

សេចក្តីភ្ជាប់ : (ឈ្មោះ) គំនូសដ្យាក្រាម នៃយានយន្ត



រថយន្តទេសចរណ៍
ម៉ាសអនុញ្ញាតអតិបរមា ស្មើនឹង ៣ ៥០០ គក្រ.
កៅអីអ្នកដំណើរអតិបរមាចំនួន០៨(បន្ថែមពីលើ
កៅអីអ្នកបើកបរ)



រថយន្តបឹស(រថយន្តដឹកអ្នកដំណើរ)
កៅអីអ្នកដំណើរច្រើនជាងចំនួន០៨(បន្ថែមពីលើ
កៅអីអ្នកបើកបរ)



រថយន្តធុន(កាំម្យ៉ុង=រថយន្តរឹងគ្មានដំណ)
ម៉ាសអនុញ្ញាតអតិបរមា ច្រើនជាង ៣ ៥០០ គក្រ.



យានយន្តមានក្បាលសណ្តោង (យានយន្តមានដំណ)
ក្បាលសណ្តោង + សឺមីរ៉ឺម៉ក

Attchment : (Indicative) Diagram of Motor Vehicles



PASSENGER CAR
Maximum permissible mass of 3,500kg
Maximum of eight passenger seats(in addition to the driver's seat)



BUS (COACH)
More than eight passenger seats(in addition to the driver's seat)



RIGID TRUCK
Maximum permissible mass of more than 3,500kg

ARTICULATED VEHICLE
Tractor + Semi-trailer

ANNEX 2: REGISTRATION OF VEHICLES IN INTERNATIONAL TRAFFIC

To the Agreement between and among the Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People (hereinafter referred to as "the Annex")

The Governments of the Kingdom of Cambodia, the People's Republic of China, the Lao People's Democratic Republic, the Union of Myanmar, the Kingdom of Thailand, and the Socialist Republic of Viet Nam (hereinafter referred to as "the Contracting Parties"),

Referring to the Agreement between and among the Governments of the Lao People's Democratic Republic, the Kingdom of Thailand, and the Socialist Republic of Viet Nam for the Facilitation of Cross-Border Transport of Goods and People, originally signed on 26 November 1999 at Vientiane, amended at Yangon on 29 November 2001, acceded to by the Kingdom of Cambodia at Yangon on 29 November 2001, acceded to by the People's Republic of China on 3 November 2002 at Phnom Penh, and acceded to by the Union of Myanmar on 19 September 2003 at Dali City (hereinafter referred to as "the Agreement"),

Referring to Articles 3(b) and (n) of the Agreement to the effect that Annexes and Protocols contain technical details or time- and/or site-specific variable elements and that they form an integral part of the Agreement and are equally binding,

Referring to Article 36 of the Agreement, as amended, per which the Agreement may be signed and ratified or accepted and enter into force separately from the Annexes and Protocols,

Referring to the Ninth GMS Ministerial Conference held in Manila in January 2000, the Seventh Meeting of the Subregional Transport Forum held in Ho Chi Minh City in August 2002, and the 11th GMS Ministerial Conference held in Phnom Penh in September 2002, where the Governments agreed to a work program to finalize the Agreement and its Annexes and Protocols by 2005, and

Referring to Articles 3(j) and 12 of the Agreement, calling for this Annex to provide technical details,

HAVE AGREED AS FOLLOWS:

Article 1: Types of Motor Vehicles

A "motor vehicle" is a power-driven vehicle that is normally used for carrying people or goods by road: It also includes rigid motor vehicles, articulated vehicles (a prime mover drawing a semi-trailer), and semi-trailers (a vehicle drawn by a motor vehicle in such a manner that part of the trailer is superimposed on the motor vehicle and a substantial part of the weight of the trailer and its load is borne by the motor vehicle). However, it does not cover vehicles that are only incidentally used for carrying persons or goods by road or for drawing on the road, such as agricultural tractors or road building contracting equipment. It also does not cover rail-borne vehicles, mopeds, and motorcycles. A diagram of motor vehicles specified in this Annex is in the Attachment.

Article 2: Registration Obligation

Motor vehicles and semi-trailers used in cross-border traffic shall be registered in their Home Country in accordance with the rules set out in this Annex.

Article 3: Use of Language and Characters

In vehicle identification marks, registration certificate, and registration plates, the particulars shall be entered in English language (in block and/or lowercase letters) and Arabic numerals. The prescribed use of English language and Arabic numerals shall not prohibit the repeating of the particulars by the parallel use of national language and characters.

Article 4: Identification Marks

(a) Every motor vehicle in cross-border traffic shall bear the following identification marks:

(i) the name or the trademark of the manufacturer of the vehicle;
(ii) on the chassis or in the absence of a chassis, on the body, the manufacturer's production or serial number; and
(iii) on the engine, the engine number if such a number is placed on it by the maker (not for semi-trailers).

(b) These identification marks shall be placed in accessible positions and shall be easily legible. In addition they shall be such that they cannot be easily altered or removed.

Article 5: Registration Certificate

(a) Every motor vehicle in cross-border traffic shall carry a valid certificate of registration issued by the competent authority of its Home Country.

(b) It shall bear the following particulars:

1. Basic Information

1.1 Title: vehicle registration certificate
1.2 Name (and logo) of the issuing authority
1.3 Address and contact data of the issuing authority (optional)
1.4 Country (also via the distinguishing sign) of the issuing authority
1.5 Authentication (seal/stamp, signature)
1.6 Date of issuance of the vehicle registration certificate

2. The Registration Particulars

2.1 License plate, or registration number
2.2 The distinguishing sign of the country of registration
2.3 Date of first registration
2.4 The period of validity if not unlimited

3. The Particulars of the Owner/Holder of the Certificate

3.1 Full Name
3.2 Address

4. The Particulars of the Vehicle

4.1 Type: Truck, bus, passenger car, etc.
4.2 Body
- 4.2.1 Brand/trademark
- 4.2.2 Model/code (if applicable)
- 4.2.3 Color (RAL code)
- 4.2.4 Year of manufacture (if available)
- 4.2.5 Chassis serial number
- 4.2.6 Number of axles
- 4.2.7 Empty weight (tare) (trucks and buses) (Painting of this information on the body of the truck or bus is optional.)
- 4.2.8 Gross weight (trucks) or seat capacity (buses) (Painting of this information on the body of the truck or bus is optional.)

4.3 Engine
- 4.3.1 Brand (if different from body)
- 4.3.2 Number of cylinders
- 4.3.3 Capacity
- 4.3.4 Horsepower
- 4.3.5 Serial number

Article 6: Registration Plate

Every motor vehicle in cross-border traffic shall display its registration number on a special flat vertical plate(s) fixed at the front and at the rear of the vehicle at right angles to the vehicle's median longitudinal plane, legible at a distance of 35-40 meters. The surface of the plate may be of a reflecting material. Semi-trailers need to display the registration number at least at the rear.

Article 7: Distinguishing Nationality Sign

(a) Every motor vehicle in cross-border traffic shall in addition to its registration number, display at the rear a distinguishing sign of the Country in which it is registered. This distinguishing sign shall consist of one to three letters in capital Latin Characters, at least 0.08 meter high and with strokes at least 0.01 meter wide. The letters shall be painted in black on white background in the shape of an ellipse with the major axis horizontal.

(b) The distinguishing sign shall not be incorporated in the registration number or be affixed in such a way that it could be confused with that number or impair its legibility.

(c) The way of display shall follow the rules with respect to the registration number.

(d) The distinguishing sign for the motor vehicles of each Contracting Party shall be as follows:

Cambodia: KH

People's Republic of China: CHN

Annex 2: Registration of Vehicles in International Traffic

Lao People's Democratic Republic: LAO

Myanmar: MYA

Thailand: T

Viet Nam: VN

Article 8: Mutual Recognition

Each Contracting Party shall recognize the motor vehicle registration plate, the motor vehicle registration certificate, and the motor vehicle inspection certificate and/or inspection mark issued by the competent authority(ies) of the other Contracting Parties.

Article 9: Amendment

Any Contracting Party may propose amendments to the Annex via the Joint Committee. Such amendments shall be subject to the unanimous consent of the Contracting Parties.

Article 10: Ratification or Acceptance

The Annex is subject to ratification or acceptance of the Governments of the Contracting Parties. The same applies to an amendment to the Annex, if any.

Article 11: Entry into Force

The Annex will enter into force on the day that at least two Contracting Parties have ratified or accepted it, and will become effective only among the Contracting Parties that have ratified or accepted it. The same applies to an amendment to the Annex, if any.

Article 12: Conforming National Law

Where necessary, the Contracting Parties undertake to conform their relevant national legislation with the contents of the Annex.

Article 13: Reservations

No reservation to the Annex shall be permitted.

Article 14: Suspension of the Annex

Each Contracting Party may temporarily suspend wholly or partly the application of the Annex with immediate effect in the case of emergencies affecting its national safety. The Contracting Party will inform the other Contracting Parties as soon as possible of such suspension, which will end as soon as the situation returns to normal.

Annex 2: Registration of Vehicles in International Traffic

Article 15: Relationship with the Agreement

As a measure to implement the principles laid down in the Agreement, the Annex cannot depart from or be contrary to these principles. In case of incompatibility between the Annex and the Agreement, the latter shall prevail. In case of incompatibility between the Annex and another annex or protocol, such incompatibility shall be interpreted in light of the Agreement.

Article 16: Relationship of the Attachment to the Annex

The attachment shall form an integral part of the Annex and shall be equally binding.

Article 17: Dispute Settlement

Any dispute between or among two or more Contracting Parties on the interpretation or application of the Annex shall be settled directly or by amicable negotiation in the Joint Committee.

Article 18: Denunciation

Once entered into force, the Annex cannot be denounced separately from the Agreement.

Attachment to Annex 2: Diagram of Motor Vehicles

Annex 2: Registration of Vehicles in International Traffic

In witness whereof, the undersigned, being duly authorized, have signed this Annex.

Done at Phnom Penh on 30 April 2004 in six originals in the English language.

Signed:

For the Royal Government of Cambodia

....

His Excellency Tram Iv Tek
Secretary of State, Ministry of Public Works and Transport

For the Government of the People's Republic of China

....

His Excellency Hu Xijie
Vice Minister of Communications

For the Government of the Lao People's Democratic Republic

....

His Excellency Sommad Pholsena
Vice Minister of Communication, Transport, Post and Construction

For the Government of the Union of Myanmar

....

His Excellency Thura Thaung Lwin
Deputy Minister of Rail Transportation

For the Government of the Kingdom of Thailand

....

His Excellency Nikorn Chamnong
Deputy Minister of Transport

For the Government of the Socialist Republic of Viet Nam

....

His Excellency Pham The Minh
Vice Minister of Transport

Attachment: (Indicative) Diagram of Motor Vehicles

PASSENGER CAR
Maximum permissible mass of 3,500kg
Maximum of eight passenger seats (in addition to the driver's seat)



BUS (COACH)
More than eight passenger seats (in addition to the driver's seat)

RIGID TRUCK
Maximum permissible mass of more than 3,500kg

ARTICULATED VEHICLE
Tractor + Semi-trailer

Note: The references to weight above are for the sole purpose of categorizing vehicles.

ឧបសម្ព័ន្ធទី ៤

ការសម្របសម្រួលបែបបទឆ្លងកាត់ព្រំដែន

ភ្ជាប់ទៅនឹងកិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាពមីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍
និងសាធារណរដ្ឋសង្គមនិយមវៀតណាម
ស្តីអំពីការសម្របសម្រួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន
(តទៅហៅកាតថា " ឧបសម្ព័ន្ធ ")

រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សហភាព មីយ៉ាន់ម៉ា ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋ សង្គមនិយមវៀតណាម (តទៅហៅកាត់ថា" ភាគីចុះកិច្ចសន្យា")

ដោយយោងទៅផល់" កិច្ចព្រមព្រៀងរវាង និងក្នុងរង្វង់រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា សាធារណរដ្ឋប្រជាមានិតចិន សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីអំពីការសម្របសម្រួលនូវការដឹកជញ្ជូនទំនិញ និងពលរដ្ឋឆ្លងកាត់ព្រំដែន ដែលបានចុះហត្ថលេខាតំបូង នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៩ នៅវៀងច័ន្ទ និងធ្វើវិសោធនកម្ម នៅថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០០១ នៅយ៉ាងហ្គូន . ដែលបានយល់ព្រមចូល ដោយព្រះរាជាណាចក្រកម្ពុជា នៅយ៉ាងហ្គូន នៅថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ២០០១ បានយល់ព្រមចូល ដោយសាធារណរដ្ឋប្រជាមានិតចិន នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ ២០០២ នៅភ្នំពេញ និងបានយល់ព្រមចូល ដោយសហភាពមីយ៉ាន់ម៉ា នៅថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៣ នៅទីក្រុងដាលី តទៅហៅកាត់ថា" កិច្ចព្រមព្រៀង"

ដោយយោងទៅផល់មាត្រាទី . ៣(បេ)និង(អិន)នៃកិច្ចព្រមព្រៀង ដែលបានចែងថា ឧបសម្ព័ន្ធ និងពិធីសារទាំងឡាយ ដែលមានលំអិតខាងបច្ចេកទេស ឬពេលវេលា និង/ឬ សមាសធាតុផ្សេងៗគ្នាទាំងឡាយដែលមានលក្ខណៈពិសេស ទៅតាមទីកន្លែង ហើយដែលឯកសារទាំងអស់នេះបង្កើតជាផ្នែកពាក់ព័ន្ធចូលរួមនៃកិច្ចព្រមព្រៀង នឹងមានតំលៃចូលរួមស្មើៗគ្នា

ដោយយោងទៅផល់ មាត្រាទី៣៦ នៃកិច្ចព្រមព្រៀង ដែលបានធ្វើវិសោធនកម្មរួចហើយ ដែលឧបសម្ព័ន្ធ និងពិធីសារនិមួយៗអាចត្រូវបានគេចុះហត្ថលេខា ផ្តល់សច្ចាប័ន និងចូលជាធរមាន ដោយឡែកៗពីគ្នា ដាច់ចេញអំពីកិច្ចព្រមព្រៀង

ដោយយោងទៅផល់ កិច្ចប្រជុំលើកទី៩ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ានិលឡា ក្នុងខែមករា ឆ្នាំ ២០០០. កិច្ចប្រជុំលើកទី៧ នៃវេទិកាដឹកជញ្ជូនតំបន់ ដែលបានប្រព្រឹត្តិទៅនៅទីក្រុងហូជីមិញ ក្នុងខែសីហា ឆ្នាំ ២០០២ និងកិច្ចប្រជុំលើកទិ១១ រដ្ឋមន្ត្រី GMS ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ក្នុងខែកញ្ញា ឆ្នាំ ២០០២ ដែលរដ្ឋមន្ត្រី GMS ទាំងអស់ បានឯកភាពយល់ព្រមទៅនឹងផែនការការងារមួយ ក្នុងការបង្ហើយបញ្ចប់កិច្ចព្រមព្រៀង និងឧបសម្ព័ន្ធ-ពិធីសាររបស់វា ក្នុងឆ្នាំ ២០០៥

ដោយយោងទៅផល់ មាត្រាទី៤ នៃកិច្ចព្រមព្រៀង ដែលបានស្នើឱ្យផ្តល់ការរៀបចំលំអិត ខាងបច្ចេកទេស តាមរយៈឧបសម្ព័ន្ធនេះ

បានព្រមព្រៀងគ្នាដូចខាងក្រោម :

មាត្រា ១.- គោលបំណង

ភាគីចុះកិច្ចសន្យា ត្រូវព្យាយាមក្នុងការរៀបចំ ឱ្យបានប្រសើរបំផុតទៅតាមលទ្ធភាព ដើម្បីរៀបចំទំរង់បែបបទដឹកជញ្ជូនឆ្លងកាត់ និងសំរបសំរួល តាមរយៈប្រព្រឹត្តិកម្មងាយស្រួល មានប្រសិទ្ធភាពនិង រហ័ស ។

មាត្រា ២.- វិសាលភាព

ឧបសម្ព័ន្ធនេះ អនុវត្តទៅលើគ្រប់ចលនាដឹកជញ្ជូនឆ្លងកាត់ព្រំដែន នូវមនុស្សម្នា យានយន្ត និងទំនិញ តាមផ្លូវគោក ដែលជាផ្នែកមួយ នៃកិច្ចប្រតិបត្តការដឹកជញ្ជូនតាមបែបពហុរូបភាព។

មាត្រា ៣.- ការពិគ្រោះយោបល់, សហប្រតិបត្តិការ, ការសំរបសំរួល និង ការធ្វើអោយចុះសំរុងគ្នា

ក- ភាគីចុះកិច្ចសន្យា នឹងពិគ្រោះពិភាក្សាគ្នា នៅឯគណៈកម្មការរួម អំពីការបកស្រាយខុសគ្នាណាមួយដែលរាយការណ៍អំពីចលនាដោយរលូននៃទំរង់បែបបទឆ្លងកាត់ព្រំដែន ដែលនឹងត្រូវធ្វើឱ្យបានរហ័ស នូវនីតិវិធី និងការអនុវត្តន៍ទាំងឡាយ ដើម្បីកាត់បន្ថយ នូវការអនុវត្តន៍បែបបទមិនត្រឹមត្រូវទាំងឡាយ នោះ ។

ខ- ភាគីចុះកិច្ចសន្យា នឹងធ្វើការសំរបសំរួលប៉ុស្តិ៍ត្រួតពិនិត្យច្រកព្រំដែនរបស់ពួកគេ ដោយគោរពទៅតាមចំនុចដូចខាងក្រោម :

- ពេលម៉ោងប្រតិបត្តិការ ។
- ប្រភេទសេវាកម្មត្រួតពិនិត្យដែលអត្ថិភាព នៅតាមចំណុចឆ្លងកាត់ព្រំដែនរៀង១ខ្លួន (គយ, ចត្តាឡីស័ក ភូតគាមអនាម័យ ការត្រួតពិនិត្យ/ការឆែកឆេរគុណភាព, សុខភាព, អន្តោប្រវេសន៍...) ។ល។ និង
- ប្រភេទទំនិញអ្វីខ្លះដែលជាកម្មវត្ថុ ត្រូវទៅនឹងប្រភេទនៃការជំរះបែបបទឆ្លងកាត់ព្រំដែន ។

ដោយមានយោងផងដែរនៅក្នុងពិធីសារ ទី១ នៅឯស្ថានីយ៍ឆ្លងកាត់ព្រំដែន សេវាត្រួតពិនិត្យទាំងឡាយ នឹងត្រូវ គេបើកអោយដំណើការ២៤ ម៉ោងក្នុង ១ថ្ងៃ, ៧ថ្ងៃ ក្នុង ១ សប្តាហ៍, ទាំងតាមរយៈមន្ត្រីប្រចាំនៅអចិន្ត្រៃយ ឬការបើកតាមរយៈការស្នើសុំ នៅពេលមានការជូនដំណឹងណាមួយជាមុន ដើម្បីធានាឱ្យមានការជំរះបែបបទ នៅក្រៅម៉ោងធ្វើការការងារធម្មតាឬដោយឡែកផ្សេងទៀត ដែលត្រូវមានការសំរបសំរួលគ្នា រវាងភាគីពីរប្រទេសជាប់គ្នា ។

គ- ភាគីចុះកិច្ចសន្យា ត្រូវធ្វើការសំរបសំរួលគ្នា ការត្រួតពិនិត្យរបស់ពួកគេ នឹង/ ឬ នីតិវិធី និងការអនុវត្តន៍ក្នុងការជំរះបែបបទទាំងឡាយ ដែលកំពុងប្រើប្រាស់ (ឧទាហរណ៍ៈការត្រួតពិនិត្យរួមគ្នាបង្អួចតែមួយ) ។

ឃ- ភាគីចុះកិច្ចសន្យាត្រូវទទួលអនុវត្តក្នុងការធ្វើអោយចុះសំរុងគ្នា នូវមធ្យោបាយឧបករណ៍ខាងអេឡិចត្រូនិក ឬក៏មធ្យោបាយទំនាក់ទំនងផ្សេងទៀត រួមទាំងគ្រឿងប្រដាប់ដើម្បីកត់ត្រាទិន្នន័យ, និងកម្មវិធីផ្នែកទន់ (Software) ជាមួយនឹងប្រពន្ធ័ទាំងឡាយដែលកំពុងប្រើប្រាស់ ដោយភាគីចុះកិច្ចសន្យាផ្សេងទៀត នៅពេលដែលមានការផ្តល់សញ្ញាណថ្មី, ការប្តូរផ្លាស់ និង ការធ្វើបច្ចុប្បន្នកម្ម នូវប្រពន្ធ័ទាំងនោះ ។

មាត្រា ៤.- ការត្រួតពិនិត្យរួមគ្នា បង្អួចតែមួយ

ក- ភាគីចុះកិច្ចសន្យាត្រូវចាត់វិធានការចាំបាច់ ក្នុងអភិវឌ្ឍន៍ឱ្យរីកចំរើនឡើងនូវការឆែកឆេរ និងការត្រួតពិនិត្យក្នុងពេលព្រម១គ្នា របស់អជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ ទៅលើ មនុស្សម្នា ទំនិញ និង យានយន្ត។

ខ- **បែបផែនជាក់ស្តែង** (Modalities)

នីតិវិធីនៃការត្រួតពិនិត្យរួមគ្នាបង្អួចតែមួយ អាចសំរេចទៅបាន តាមរយៈសកម្មភាពការងារដំណាល១គ្នាពេលតែមួយ របស់អជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់។

ជំរើសក្រៅពីនេះ អាជ្ញាធរដទៃទៀត តាមការស្នើសុំ អាចផ្ទេរសមត្ថកិច្ចការងាររបស់ពួកគេ ពីអាជ្ញាធរមួយ ជូនទៅអជ្ញាធរមួយទៀត ដែលមានវត្តមាននៅច្រកព្រំដែន(ឧទាហរណ៍: អជ្ញាធរគយ) ក្នុងការបំពេញ ការងារនោះ នៅក្នុងនាមរបស់ពួកគេ ។

មាត្រា ៥ .. ការត្រួតពិនិត្យគយ រួមគ្នាតែមួយលើក

ភាគីចុះកិច្ចសន្យា ទទួលធ្វើកិច្ចសហប្រតិបត្តិការដើម្បីធ្វើឱ្យសំរេចការអនុវត្តនីការត្រួតពិនិត្យរួមគ្នាតែមួយ លើកចំពោះការត្រួតពិនិត្យខាងគយ ។

ក- និយមន័យ

ការត្រួតពិនិត្យគយរួមគ្នាតែមួយលើក គឺជាកម្មវត្ថុនៃប្រតិបត្តិការដឹកជញ្ជូន ក្នុងការត្រួតពិនិត្យគយតែមួយលើកគត់ ក្នុងគោលបំណងឆ្លងកាត់ព្រំដែន រវាងពីរប្រទេស ដែលស្រុះស្រួលគ្នា ។

ខ- ការស្នើឡើងនូវបែបផែនជាគំរូ (Suggested Modalities)

ការត្រួតពិនិត្យគយរួមគ្នាតែមួយលើក អាចអនុវត្តសំរេចទៅបាន ទៅតាមវិធីទាំងឡាយ ជាឧទាហរណ៍ដូចខាងក្រោម (តារាងមិនទាន់គ្រប់ជ្រុងជ្រោយមួយ) :

១- កាត្រួតពិនិត្យរួមគ្នា
អជ្ញាធរគយជាតិរវាងពីរភាគីដែលស្រុះស្រួលគ្នា ត្រូវអនុវត្តការត្រួតពិនិត្យ និងការឆែកឆេររួមគ្នា និងព្រមពេល ដំណាលគ្នា ។ មន្ត្រីគយនៃពីរប្រទេសស្រុះស្រួលគ្នា ត្រូវជួយគ្នាទៅវិញទៅមកក្នុងការពង្រីកលទ្ធភាពអនុវត្តសកម្មភាពការងាររបស់ពួកគេ ។

២- ការរៀបចំដាច់ដោយឡែកពីគ្នា
អជ្ញាធរគយពីភាគីចុះកិច្ចសន្យាមួយ ត្រូវរៀបចំជំនាញពិសេស ក្នុងការងារពិសេសណាមួយ នៅពេលដែលអជ្ញាធរគយពីភាគីចុះកិច្ចសន្យាមួយផ្សេងទៀត រៀបចំជំនាញពិសេស សំរាប់ការងារផ្សេងណាមួយទៀត ជាឧទាហរណ៍ ឱ្យស្របទៅតាមទិដៅចរាចរ(ទិសដៅចេញក្រៅ ឬទិសដៅចូលក្នុង) ឬក៏ប្រភេទនៃការដឹកជញ្ជូន (អ្នកដំណើរ ឬទំនិញ) ។

៣- សកម្មភាពនៅលើទឹកដីប្រទេសដទៃផ្សេងទៀត
មន្ត្រីគយពីភាគីចុះកិច្ចសន្យាមួយ អាចអនុញ្ញាតឱ្យធ្វើសកម្មភាពការងាររបស់ពួកគេ នៅលើទឹកដីនៃភាគីចុះកិច្ចសន្យាផ្សេងទៀត ។

៤-ការផ្ទេរសិទ្ធិនៃអជ្ញាធរ /ការទទួលស្គាល់ទៅវិញទៅមកនូវការត្រួតពិនិត្យ
ភាគីចុះកិច្ចសន្យាមួយ អាចផ្ទេរសិទ្ធ ខាងសមត្ថកិច្ចនៃការត្រួតពិនិត្យ និងការឆែកឆេររបស់ខ្លួន ទៅឱ្យមន្ត្រីគយនៃភាគីចុះកិច្ចសន្យាដែលស្រុះស្រួលគ្នាមួយផ្សេងទៀតដើម្បីធ្វើសកម្មភាពនៅក្នុងនាមរបស់ខ្លួន ។ ភាគីចុះកិច្ចសន្យា ត្រូវទទួលស្គាល់គ្នាទៅវិញទៅមក ការត្រួតពិនិត្យឆែកឆេរ ដោយអជ្ញាធរគយនិមួយៗផ្សេងទៀត

៥-ការរួមបញ្ចូលគ្នា :
ការរួមបញ្ចូលគ្នា នៃបែបផែនជាគំរូដូចការកត់សំគាល់ខាងលើ អាចអនុវត្តបាន ។

គ- ការអនុវត្តន៏ដោយ អនុស្សារណៈនៃការយោគយល់ (MOU)

បែបផែនជាគំរូពិសេសមួយ នូវនិតិវិធីនៃការត្រួតពិនិត្យរួមគ្នាតែមួយលើក និងត្រូវព្រមព្រៀងគ្នាដោយគូរភាគីនៃប្រទេសមានព្រំដែនជាប់គ្នា តាមរយៈអនុស្សារណៈនៃការយោគយល់ជាទ្វេភាគី ទៅតាមចំណុចនៃច្រកព្រំដែននិមួយៗ ដែលមានបញ្ជាក់ក្នុងពិធីសារទី១ ។

មាត្រា ៦.- ការធ្វើឱ្យស៊ីចង្វាក់គ្នា ការធ្វើឱ្យងាយស្រួលសាមញ្ញ និងភាសានៃឯកសារនានាទាំងឡាយ

ក- ការធ្វើឱ្យស៊ីចង្វាក់គ្នា :

ភាគីចុះកិច្ចសន្យាត្រូវព្យាយាមបន្ថែមទៀត នូវការប្រើប្រាស់ឯកសារពាក់ព័ន្ធទាំងឡាយ សំរាប់ទំរង់បែបបទ នានានៃការឆ្លងកាត់ព្រំដែន ឱ្យស្របទៅតាមកំរិតស្តង់ដារ និងការអនុវត្តន៏ជាអន្តរជាតិនានា ((ឧទាហរណ៏ ដូចជា: គំនូសបង្ហាញជាគន្លឹះរបស់អង្គការសហប្រជាជាតិ សំរាប់ទំនិញ) មើលឯកសារភ្ជាប់នឹង ឧបសម្ព័ន្ធនេះ) ។

ខ- ការធ្វើឱ្យងាយស្រួលសាមញ្ញ

ភាគីចុះកិច្ចសន្យាត្រូវកំរិត និង/ឬបន្ថយ និងបំបាត់ចោល នូវចំនួនឯកសារសំរាប់ជំរះបែបបទឆ្លងកាត់ព្រំដែន និងជំរុញអនុវត្តនូវនិតិវិធី និងឯកសារទាំងឡាយ ដែលត្រូវការសំរាប់ទំរង់បែបបទឆ្លងកាត់ព្រំដែនទៅតាមចំនួនដែលអាចធ្វើទៅបាន ។

គ- ភាសា

រាល់ឯកសារទាំងអស់ត្រូវបានសរសេរឡើងជាភាសាអង់គ្លេសបន្ថែមទៅលើឯកសារដែលសរសេរជាភាសារបស់ជាតិ។ នៅក្នុងករណី ឬព្រឹត្តិហេតុដែលមានការបកស្រាយខុសគ្នាណាមួយទៅលើអត្ថន័យ នោះច្បាប់ជាភាសា អង់គ្លេស ត្រូវយកធ្វើជាសេចក្តីយោង ។

មាត្រា ៧.- ការផ្លាស់ប្តូរពត៏មាន

ភាគីចុះកិច្ចសន្យា ត្រូវផ្លាស់ប្តូរគ្នា តាមរយៈលេខាធិការដ្ឋាននៃគណៈកម្មាធិការរួម នូវពត៌មានយ៉ាងទូលំទូលាយ ជាភាសាអង់គ្លេស អំពីបទបញ្ញត្តិ ច្បាប់ ទំរង់បែបបទ និតិវិធី និងការអនុវត្តន៏ និងការផ្លាស់ប្តូរ ជាបន្តបន្ទាប់ បែបបទក្នុងការឆ្លងកាត់ ព្រំដែន។ ពត៌មានទាំងអស់នេះ ជាការល្អ អាចផ្សព្វផ្សាយតាមរយៈការចុះផ្សាយតាមអិនធើណែត។

មាត្រា ៨.- ការផ្តល់គ្នាជាមុន នូវពត៌មាននៃការជំរះ បែបបទទំនិញ

តាមតែអាចមាន អាជ្ញាធរ នៃប្រទេសចេញដំណើរ(ដើម) ត្រូវផ្ញើ ឯកសារជំរះបែបបទឆ្លងកាត់ព្រំដែនដែលពាក់ពន្ធ័ ទៅអោយអាជ្ញាធរភាគីជាម្ចាស់ផ្ទះ នៃការធ្វើដំណើរឆ្លងកាត់របស់ពួកគេ ទៅតាមមធ្យោបាយសមរម្យទាំងអស់ នៃការទំនាក់ទំនង(អ្នកនាំពាក្យ. សំបុត្រ. ទូរសារ. ទូរពុម្ព. ទំរង់ពត៌មានអេឡិចត្រូនិក ")

មាត្រា ៩.- លំដាប់អាទិភាពនៃការជំរះបែបបទឆ្លងកាត់ព្រំដែន

អាទិភាពសំរាប់ការបំពេញទំរង់បែបបទ ឆ្លងព្រំដែនមានលំដាប់ដូចខាងក្រោម ដោយមិនមានការជំទាស់ទៅនឹងបទបញ្ញត្តិខាងភូតគាមអនាម័យ :

១-អ្នកជំងឺ .និងអ្នកដំណើរទាំងឡាយ

២-ទំនិញងាយខូចរលួយ. (រាប់ទាំងម្ហូបអាហារស្រស់)

៣-សត្វរស់

៤-ទំនិញផ្សេងៗទៀត

មាត្រា ១០.- ការកាត់បន្ថយ នូវការអនុវត្តន៍ការត្រួតពិនិត្យរូបវន្ត(ជាក់ស្តែង) ជាប្រចាំ និងជិតដល់បំផុត

ក- ភាគីចុះកិច្ចសន្យាត្រូវព្យាយាម ក្នុងការកាត់បន្ថយ នូវការអនុវត្តន៍ការត្រួតពិនិត្យជារូបវន្ត (ជាក់ស្តែង)ជាប្រចាំនិងជិតដល់បំផុត នៅពេលដែលមិនមានការចាំបាច់ដាច់ខាត ដល់ផលប្រយោជន៍ ប្រទេសជាម្ចាស់ផ្ទះ

ខ- ទំនិញឆ្លងកាត់ពុំមានហានិភ័យ សំរាប់ការធ្វើអោយឆ្លងរោគ និងហានិភ័យ ខាងសុវត្ថិភាពផ្សេងទៀត សំរាប់ប្រទេសឆ្លងកាត់ អាចត្រូវកំណត់អោយឆ្លងការត្រួតពិនិត្យអនាម័យ និងការត្រួតពិនិត្យផ្សេងៗទៀត ដោយមិនមានខូចប្រយោជន៍ ឬជំទាស់ទៅនឹង ការព្យាបាលមិនឱ្យឆ្លងមេរោគ និងការត្រួតពិនិត្យមើលមធ្យោបាយនៃការដឹកជញ្ជូន ។

គ- ការត្រួតពិនិត្យគយអាចធ្វើទៅបាន តាមការសាកល្បងលើគំរូជ្រើសរើស ដែលនឹងបំពេញបន្ថែម ដោយការត្រួតពិនិត្យ នៅពេលណាដែលគេសង្ស័យថា មានករណីមិនធម្មតាណាមួយ ។

មាត្រា ១១.- អត្ថិភាពជាតំរូវការខាងមធ្យោបាយ និងមន្ត្រី

ភាគីចុះកិច្ចសន្យា ត្រូវមើលឃើញថា តំរូវការខាងមធ្យោបាយ និង មន្ត្រីសំរាប់សកម្មភាពស្នើរលូន នៃទំរង់បែបបទឆ្លងកាត់ព្រំដែន (ដូចបានរៀបចំ ក្នុងឧបសម្ព័ន្ធទី១២) ត្រូវមានអត្ថិភាព នៅចំនុចឆ្លងកាត់ ដូចដែលបានកំណត់ក្នុងពិធីសារទី១ ។

មាត្រា ១២.- ការធ្វើវិសោធនកម្ម

ភាគីចុះកិច្ចសន្យាណាមួយក៏ដោយ អាចស្នើធ្វើវិសោធនកម្ម លើឧបសម្ព័ន្ធ តាមរយៈគណកម្មាធិការរួម ។ ការធ្វើវិសោធនកម្មនោះ ត្រូវតែជាកម្មវត្ថុនៃការឯកភាពគ្នាជាឯកច្ឆ័ន ពីភាគីចុះកិច្ចសន្យាទាំងអស់ ។

មាត្រា ១៣.- ការផ្តល់សច្ចាប័ន និងការយល់ព្រម

ឧបសម្ព័ន្ធនេះ ជាកម្មវត្ថុនៃការផ្តល់សច្ចាប័ន ឬការយល់ព្រម នៃរដ្ឋាភិបាលទាំងឡាយដែលជាភាគីចុះកិច្ចសន្យា។ ការអនុវត្តន៍ដូចគ្នានេះ ត្រូវបានគេយកមកប្រើ ក្នុងការធ្វើវិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ១៤.- ការចូលជាធរមាន

ឧបសម្ព័ន្ធ នឹងត្រូវចូលជាធរមាន នៅថ្ងៃដែល ០២ភាគីចុះកិច្ចសន្យាយ៉ាងតិច បានផ្តល់សច្ចាប័ន ឬការយល់ព្រមដល់ឧបសម្ព័ន្ធនេះ នឹងត្រូវមានប្រសិទ្ធភាពត្រឹមតែក្នុងរង្វង់ភាគីចុះកិច្ចសន្យា ដែលបានផ្តល់ សច្ចាប័ន ឬការយល់ព្រមទទួលយកឧបសម្ព័ន្ធ។ ការអនុវត្តន៍ដូចគ្នានេះត្រូវបានគេអនុវត្តក្នុងការធ្វើ វិសោធនកម្មលើឧបសម្ព័ន្ធ ប្រសិនបើមាន។

មាត្រា ១៥.- ការកែសំរួលច្បាប់ជាតិ

នៅចំណុចណាដែលចាំបាច់ ភាគីចុះកិច្ចសន្យា ត្រូវធានាធ្វើការកែសំរួលច្បាប់ជាតិដែលពាក់ព័ន្ធ ឱ្យស្របទៅតាមខ្លឹមសារនៃឧបសម្ព័ន្ធ។

មាត្រា ១៦.- ការដាក់លក្ខខ័ណ្ឌ

ការដាក់លកខ័ណ្ឌ ទៅលើឧបសម្ព័ន្ធ មិនត្រូវបានគេអនុញ្ញាតិឡើយ ។

មាត្រា ១៧.- ការព្យួរទុកនៃឧបសម្ព័ន្ធ

ភាគីចុះកិច្ចសន្យានិមួយៗអាចព្យួរទុក ជាបណ្តោះអាសន្ន នូវការអនុវត្តន៍ឧបសម្ព័ន្ធទាំងស្រុង ឬក៏មួយចំណែក ដែលមានប្រសិទ្ធិភាពភ្លាមៗ នៅក្នុងករណីមានការរីករាលជាអាសន្ន ដែលប៉ះពាល់ដល់សុវត្ថិភាពរបស់ជាតិខ្លួន។ ភាគីចុះកិច្ចសន្យា នឹងជូនពត៌មានទៅភាគីចុះកិច្ចសន្យាផ្សេងទៀត ភ្លាម តាមតែអាចធ្វើទៅបាន អំពីការព្យួរទុកនេះ និងការបញ្ចប់ការព្យួរទុកនេះ ឱ្យបានឆាប់បំផុត នៅពេលណា ដែលសភាពការណ៍ វិលត្រឡប់ទៅរកស្ថានភាពជាធម្មតាឡើងវិញ។

មាត្រា ១៨.- សង្គតិភាព ជាមួយកិច្ចព្រមព្រៀង

ដោយសារតែវាជាវិធានការមួយក្នុងការអនុវត្តន៍គោលការណ៍ទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ឧបសម្ព័ន្ធនេះមិនអាចផ្តាច់ចេញ ឬក៏ក្លាយជាផ្ទុយទៅនឹងគោលការណ៍ទាំងនោះ។ នៅក្នុងករណីដែលវិសមិត (មិនចុះសំរុងគ្នា-មិនត្រូវគ្នា) រវាងពិធីសារ និងកិច្ចព្រមព្រៀង នោះកិច្ចព្រមព្រៀងត្រូវយកជាបានការ-ជាគោល។ នៅក្នុងករណីដែលវិសមិត(មិនចុះសំរុងគ្នា-មិនស៊ីគ្នា)រវាងឧបសំព័ន្ធ និងឧបសម្ព័ន្ធ ឬពិធីសារផ្សេងទៀតនោះ វិសិមិតភាពនេះ ត្រូវយកទៅបកស្រាយជាមួយគ្នា នឹងកិច្ចព្រមព្រៀង។

មាត្រា ១៩.- ទំនាក់ទំនង ជាមួយឯកសារដែលចងភ្ជាប់ទៅនឹងឧបសម្ព័ន្ធ

ឯកសារភ្ជាប់ ត្រូវបង្កើតជាផ្នែករួមបញ្ចូលគ្នាមួយ ជាមួយឧបសម្ព័ន្ធ និងត្រូវមានតំលៃចូលរួមស្មើៗគ្នា ។

មាត្រា ២០.- ការដោះស្រាយជំលោះ

ជំលោះរវាងភាគី០២ ឬច្រើន នៃភាគីចុះកិច្ចសន្យា ទៅលើការបកស្រាយ ឬការអនុវត្តន៍ឧបសម្ព័ន្ធ ត្រូវស្រុះស្រួលគ្នា លើកយកមកដោះស្រាយដោយផ្ទាល់ ឬដោយការចរចារតាមគោលការណ៍សន្តិវិធី តាមរយៈគណៈកម្មាធិការរួម។

43. In practical applications, a company using the one-run method for completion of trade documents establishes a company master to cover all relevant forms needed for a trade transaction. In countries where a national master has been established, the master form can, in principle, be used as the company master. The forms needed for a trade transaction include - in addition to mandatory international and national standard forms - a number of other forms, adapted to the particular needs of the company concerned, with company name and logotype pre-printed and sometimes reflecting other company characteristics. The detailed design of these "company forms" is left to the discretion of the issuing company. Some forms intended for general application, such as commercial invoices, bills of lading, etc , are commercially available in aligned neutral versions.

United Nations Layout Key for Trade Documents

Consignor (Exporter)	Date; Reference No. etc.
Consignee	Buyer (if other than original consignee) or other address
Notify or delivery address	Country whence consigned / Country of origin / Country of destination
Transport details	Terms of delivery and payment

Shipping marks; Container No.	Number & kind of packages; Goods description	Commodity No.	Gross weight / Net quantity	Cube / Value

Free disposal

Place and date of issue; Authentication

Recommendation 1

(តទៅរាជកិច្ចលេខ ៩២)

ព្រះរាជក្រឹត្យ

នស/រកត/១១០៦/៤៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី២០ ខែមិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ និងអនុប្រធានទី២ ព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រមុខរដ្ឋស្តីទី

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង :

១-ឯកឧត្តម **សយ ស៊ីផាន់ណា** ជាទីប្រឹក្សាសម្តេចប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

២-ឯកឧត្តម **ចាន់ សឿន** ជាជំនួយការសម្តេចប្រធានព្រឹទ្ធសភា បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

មាត្រា ២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៦១១.៤៩៤

លេខ : ៤៥៧ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃឹម ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៤៧៨

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរិវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោក ទូច សៀ

ជា

ឧកញ៉ា

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០៦

ល្អងព្រះបរមនាម និង តាមព្រះរាជឡោងបង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣រព.០៦១២.៥០៦

លេខ : ៤៥១ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៤៨០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះ :

-ឯកឧត្តម ចាន់ សារុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ខ-គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់ មហាសេនា ចំពោះ :

-ឯកឧត្តម ចាន់ តុងអ៊ីវ រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣រល.០៦១២.៥០៨

លេខ : ៤៥៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៤៩១

យើង

ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៩/នស/៩៤ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- បានទ្រង់យល់ក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដីនៃរដ្ឋកម្ពុជា
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១: ត្រូវបានអនុញ្ញាតជូនលោកចៅក្រម **សៅ មៀច** បន្តបម្រើការងារជាចៅក្រមនៅតុលាការក្រុងភ្នំពេញ មួយរយៈពេលទៀត ។

មាត្រា២: បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣: សម្ដេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ.ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៦

គួចព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្ដីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

៣.រល.០៦១២.៥០៩

លេខ: ៤៥៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ: ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៦

អគ្គលេខាធិការនៃរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២០៦/៥៩២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម សៀង ណាំ

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និង តាមព្រះរាជគ្រាស់បង្គាប់
ប្រមុខរដ្ឋស្តីទី
ហត្ថលេខា និងព្រះរាជលញ្ឆករ
ជា ស៊ីម

៣៧.០៦១២.៥១០

លេខ : ៤៥៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០០៦
អគ្គលេខាធិការរងរាជរដ្ឋាភិបាល
ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

សំណុំរឿង

លេខ :១១៣ /០១៣ /២០០៦

ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦

សេចក្តីសម្រេច

លេខ :០៨៨/០១៥/២០០៦ កបធ.ច

ចុះថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦

ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញលិខិតលេខ ១២៤១ រស ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្នើសុំអោយក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៤ និង មាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០០៦ វេលាម៉ោង ១៥ និង ៤០ នាទី

ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍

ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

- យល់ឃើញថា សំណើរបស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើនេះមកពិនិត្យបាន។
- យល់ឃើញថា មាត្រា ១៤ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១៤ ថ្មី ដោយគ្រាន់តែលុបពាក្យ "***តែ ១ ដងគត់***" ក្នុងឃ្លាទី ២ ចំណុចទី ១ ។

- យល់ឃើញថា មាត្រា ៥៧ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៥៧ ថ្មី ដោយគ្រាន់តែកែសម្រួលពី " *ដោយគណៈកម្មការពិសេសមួយដែលតែងតាំងដោយរាជរដ្ឋាភិបាល* " មក " *ដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ* " ។

ការធ្វើវិសោធនកម្មខាងលើនេះ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញ នោះទេ ។

សម្រេច

មាត្រា ១.- ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជាដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៥ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របទាំងស្រុង កាលពីថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០៦ នាសម័យប្រជុំព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

មាត្រា ២.- សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៦

ជ.ក្រុមប្រឹក្សាធម្មនុញ្ញ

ប្រធាន

បិន ឈិន

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ១៤៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា១៦ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

~~~~~~~~~

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
~~~~~~~~~

- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យភូតគាមអនាម័យ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា មួយ.-

មាត្រា១៦ នៃអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានកែសម្រួល ដូចខាងក្រោម :

មាត្រា ១៦ថ្មី.-

- ផ្នែកទី១ :

ក្រុមត្រួតពិនិត្យនៅស្ថានីយអ្នកដំណើរអន្តរជាតិ មានសមាសភាព :

- មន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការដ្ឋាននគរបាលជាតិក្រសួងមហាផ្ទៃ ប្រធាន
- មន្ត្រីគយ និងរដ្ឋាករនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- មន្ត្រីកាំកុងត្រូលនៃក្រសួងពាណិជ្ជកម្ម សមាជិក
- មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- កម្លាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

• ផ្នែកទី២ :

ក្រុមត្រួតពិនិត្យនៅមណ្ឌលឃ្លាំងទំនិញ មានសមាសភាព :

- មន្ត្រីគយ និងរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធាន
- មន្ត្រីនគរបាលជាតិ នៃនាយកដ្ឋានអន្តោប្រវេសន៍ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក
- មន្ត្រីកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម សមាជិក
- មន្ត្រីត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- មន្ត្រីភូតគាមអនាម័យ នៃក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ សមាជិក
- កម្លាំងសន្តិសុខ នៃក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ សមាជិក

ចំនួនសហការីនៃក្រុមត្រួតពិនិត្យ នៅស្ថានីយអ្នកដំណើរអន្តរជាតិ និងមណ្ឌលឃ្លាំងទំនិញ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដោយមានការឯកភាពពីក្រសួង ស្ថាប័ន សាមីនីមួយៗ ។

មាត្រា ពីរ.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា បី.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃក្រសួង ស្ថាប័ន និងអភិបាលខេត្ត ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០០៦

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សុខ អាន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៤៣ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ , ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ , ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ , ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សំរេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ៦.០០០ លានរៀល (ប្រាំមួយពាន់លានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច) ជូនទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយការងារពិសេសរបស់រាជរដ្ឋាភិបាល ការទូទាត់សោហ៊ុយក្រៅប្រទេស និង ចំណាយដឹកជញ្ជូនប្រតិភូជាន់ខ្ពស់របស់អង្គភាពអាកាសចរណ៍រាជរដ្ឋាភិបាល ឆ្នាំ ២០០៦ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤៤ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ . ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ . ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ . ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ . ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ . ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធ ហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០ ន.ស ៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ . ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៥/០៤០ . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក . ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក . ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែមនិង កែសំរួលនាយកដ្ឋានមួយចំនួន នៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៥ អនក្រ.បក . ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៥ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០៦
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកាចំនួន ១.០០០ លានរៀល (មួយពាន់លានរៀលគត់) ពីជំពូក ៤០ (ចំណាយផ្សេងៗ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) ជូនក្រសួងមហាផ្ទៃ (ផ្នែកសន្តិសុខសាធារណៈ) សំរាប់ការគ្រប់គ្រងឆ្នាំ ២០០៦ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយទូទាត់ថ្លៃផ្គត់ផ្គង់ប្រេងឥន្ធនៈក្នុងឆ្នាំ ២០០៣ ជូនក្រុមហ៊ុនកម្ពុជាតេលា ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី១៧ ខែ [illegible] ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣០៦៣ អនក្រ-តត

អនុក្រឹត្យ

ស្តីពីការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យ លេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក សោម សាត ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានបច្ចេកទេសវិទ្យុ នៃអគ្គនាយកដ្ឋានវិទ្យុជាតិកម្ពុជា នៃក្រសួងពត៌មាន ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៦៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតម្លើងឋានន្តរស័ក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត /០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ត្រី** ជូននាយនគរបាលជាតិជាន់ខ្ពស់ អគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១- លោកវរសេនីយ៍ទោ និន សាធូន អត្តលេខ ០៥៩៩
២- លោកវរសេនីយ៍ទោ ង៉ែត ឡាជា អត្តលេខ ០៨០៥
៣- លោកវរសេនីយ៍ទោ ឈៅ ស្លប៉ា អត្តលេខ ០១១៥០
៤- លោកវរសេនីយ៍ទោ អ៊ុំ សំអួន អត្តលេខ ០១២៤៥
៥- លោកវរសេនីយ៍ទោ ណំ ម៉ូមីណា អត្តលេខ ០២១២២
៦- លោកវរសេនីយ៍ទោ អួន សួប អត្តលេខ ០២២១៨ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៨ ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៦៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **ឧត្តមសេនីយ៍ឯក** ជូនលោកវរសេនីយ៍ទោ **ម៉ើន លី** អត្តលេខ ០៥៣៨ នាយនគរបាលជាតិជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៦៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការផ្ទេរភារកិច្ចនិងតែងតាំងមុខតំណែង នាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ១៩៩៦ ដែលបានប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ដូចមានឈ្មោះខាងក្រោម:

១- លោកឧត្តមសេនីយ៍ត្រី ឯក ក្រឹត្យ អត្តលេខ ០៣៤៧ ពីអនុប្រធានសេនាធិការដ្ឋាន ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ។

២- លោកឧត្តមសេនីយ៍ត្រី នួន បូផល អត្តលេខ ០២០៥ ពីស្នងការនៃស្នងការដ្ឋាននគរបាលខេត្តសៀមរាប ទៅជាអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី០៤ ខែ ធ្នូ ឆ្នាំ២០០៦
នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៧ សហវ.

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០០៦

សារាចរណែនាំ
ស្តីពីការរៀបចំផែនការលទ្ធកម្ម
១១.០៧៧

យោងអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំ ស្តីពីការរៀបចំផែនការលទ្ធកម្មត្រូវបានបង្កើតឡើង ក្នុងគោលបំណងសំរេចអោយបាននូវផែនការលទ្ធកម្មមួយ ដែលមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ប្រកបដោយភាពម្ចាស់ការ និងការទទួលខុសត្រូវខ្ពស់ ។

ការរៀបចំផែនការលទ្ធកម្ម គឺជាការកសាងកម្មវិធីការងារសំរាប់អនុវត្តកិច្ចលទ្ធកម្មប្រចាំឆ្នាំរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

ឆ្នាំ២០០៧ ជាឆ្នាំដំបូងដែលរាជរដ្ឋាភិបាល បង្កើតអោយមានផែនការលទ្ធកម្មក្នុងកំណែទំរង់ ប្រព័ន្ធលទ្ធកម្មសាធារណៈ ដើម្បីលើកកំពស់ពង្រឹងយន្តការគ្រប់គ្រងចំណាយថវិការដ្ឋ អោយមានតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ រួមចំណែកក្នុងការសន្សំសំចៃថវិការដ្ឋអោយបានកាន់តែប្រសើរឡើង ក្នុងគោលដៅបង្កើន ការជឿទុកចិត្តបានលើការគ្រប់គ្រងថវិកា។

ដើម្បីឆ្លើយតបតាមគោលបំណងខាងលើ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សូមធ្វើការណែនាំអំពីការរៀបចំផែនការលទ្ធកម្មដូចខាងក្រោម :

I.អត្ថប្រយោជន៍ នៃផែនការលទ្ធកម្ម

ផែនការលទ្ធកម្មផ្តល់នូវអត្ថប្រយោជន៍សំខាន់ៗ ដូចខាងក្រោម :

-ជំរុញការគ្រប់គ្រង ការតាមដាន និងលើកកំពស់ការអនុវត្តន៍កិច្ចលទ្ធកម្មអោយកាន់តែមានប្រសិទ្ធភាពខ្ពស់។

-បង្ហាញអោយដឹងអំពីតំរូវការទំនិញ សំណង់ សេវា ទាំងបរិមាណ និងតំលៃសរុបប្រចាំឆ្នាំ របស់ស្ថាប័ននីមួយៗ។

-ដឹងនូវចំនួនកិច្ចលទ្ធកម្ម តំលៃគំរោងនីមួយៗ តាមវិធីសាស្ត្រ តាមមុខសញ្ញា និងតាមប្រភេទលទ្ធកម្ម ។

-បញ្ជាក់ច្បាស់អំពីកិច្ចលទ្ធកម្មនីមួយៗ ដែលត្រូវដំណើរការតាមលំដាប់លំដោយ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើម

រហូតដល់ការប្រគល់-ទទួល ព្រមទាំងកាលបរិច្ឆេទ និងសមាមាត្រដែលត្រូវទូទាត់ ។

-សំរាប់ធ្វើជាមូលដ្ឋាន ក្នុងការរៀបចំកម្មវិធីចំណាយប្រចាំត្រីមាស របស់ស្ថាប័នអនុវត្តលទ្ធកម្ម ។

-សំរាប់តាមដានការអនុវត្តន៍កិច្ចលទ្ធកម្ម ដើម្បីឆ្លុះបញ្ចាំងអំពីចំណុចខ្លាំង ចំណុចខ្សោយ ឬ ការយឺតយ៉ាវក្នុងដំណើរការលទ្ធកម្ម ដែលជាបុព្វបទ នាំអោយអ្នកគ្រប់គ្រងអាចចាត់វិធានការកែលំអ ដោយលុបបំបាត់ ឬ ពង្រឹងបន្ថែម ដើម្បីធានាថា កិច្ចលទ្ធកម្មចាប់ផ្តើមបានទាន់ពេលវេលា ជៀសវាងបាននូវការយឺតយ៉ាវ ហើយជំរុញអោយមានការប្រកួតប្រជែងពេញលេញ ទទួលបាននូវ គណនេយ្យភាព តម្លាភាព និងប្រសិទ្ធភាព ខ្ពស់ ។

-សំរាប់ប្រើជារបាយការណ៍ព័ត៌មានដល់អ្នកប្រើប្រាស់ចុងក្រោយ ។

II.ភារកិច្ច របស់ស្ថាប័នអនុវត្តលទ្ធកម្ម

-ស្ថាប័នអនុវត្តលទ្ធកម្ម ចាំបាច់ត្រូវរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ របស់ខ្លួនតាមគំរូដែលបានផ្តល់ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដូចមានជូនភ្ជាប់មកជាមួយ ។

-ប្រធានស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវពិនិត្យ និងអនុម័តលើផែនការលទ្ធកម្ម រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានលទ្ធកម្ម សាធារណៈនៅសប្តាហ៍ទី១ ខែមករា នៃឆ្នាំសារពើពន្ធ ។

-រាល់គំរោងចំណាយ ដែលត្រូវអនុវត្តតាមវិធីសាស្ត្រលទ្ធកម្ម ត្រូវកត់ត្រាទាំងអស់តាមលំដាប់លំដោយ បញ្ចូលក្នុងផែនការលទ្ធកម្ម ។ ករណីមិនមានកត់ត្រា ក្នុងផែនការលទ្ធកម្ម មិនត្រូវបានអនុញ្ញាតអោយធ្វើកិច្ចលទ្ធកម្មឡើយ ហើយសាមីក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវ លើ រាល់បាតុភាពអសកម្ម ដែលនឹងកើតឡើង ជាយថាហេតុ ។

-ស្ថាប័នអនុវត្តលទ្ធកម្មត្រូវចាត់ចែងអនុវត្តកិច្ចលទ្ធកម្ម អោយបានទៀងទាត់ តាមប្រតិទិនដែលបានកំណត់ក្នុងផែនការលទ្ធកម្មប្រចាំឆ្នាំ ។ ក្នុងករណីចាំបាច់ ផែនការលទ្ធកម្មអាចកែតំរូវនៅឆមាសទី២នៃឆ្នាំសារពើពន្ធ ។

-ប្រធានស្ថាប័នអនុវត្តលទ្ធកម្មមានភារកិច្ចគ្រប់គ្រង និង ត្រួតពិនិត្យជាប្រចាំរាល់កិច្ចលទ្ធកម្មរបស់ស្ថាប័នខ្លួន ហើយត្រូវធានាអោយបានថា រាល់កិច្ចលទ្ធកម្ម រួមទាំងការងារវិសហមជ្ឈការលទ្ធកម្ម សុទ្ធតែត្រូវបានអនុវត្តយ៉ាងត្រឹមត្រូវ តាមវិធីសាស្ត្រ តាមនីតិវិធី និងតាមផែនការលទ្ធកម្ម ។

-ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តន៍គ្រប់កិច្ចលទ្ធកម្ម រួមទាំងទិន្នន័យនៃកិច្ចសន្យាទាំងអស់ និងការងារវិសហមជ្ឈការ ជូនក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈ អោយបានទៀងទាត់រៀងរាល់ខែ ។

III.មូលដ្ឋានគ្រឹះសំរាប់រៀបចំផែនការលទ្ធកម្ម

ដើម្បីកសាងបាននូវផែនការលទ្ធកម្មមួយ ដែលមានលក្ខណៈច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ហើយអាចជឿទុកចិត្តបាន មន្ត្រីលទ្ធកម្មត្រូវផ្តោតការយកចិត្តទុកដាក់ លើការងារសំខាន់ៗមួយចំនួនដូចខាងក្រោម :

-ត្រូវផ្អែកលើកញ្ចប់ថវិកាប្រចាំឆ្នាំសារពើពន្ធ ដែលបានពិភាក្សា និងបានឯកភាពជាគោលការណ៍ក្នុងពេលការពារថវិកា ដើម្បីធ្វើជាមូលដ្ឋានសំរាប់រៀបចំផែនការលទ្ធកម្ម ។

Ms

-ត្រូវប្រមូលផ្តុំនូវតំរូវការប្រើប្រាស់ប្រចាំឆ្នាំរបស់ស្ថាប័នខ្លួន ទាំងទំនិញ សំណង់ និង សេវា ដោយបែងចែកជាបីប្រភេទផ្សេងគ្នាគឺ :

- ប្រភេទ I : ទំនិញ
- ប្រភេទ II : សំណង់
- ប្រភេទ III : សេវា (សេវាកម្ម និងសេវាទីប្រឹក្សា)

-ត្រូវសិក្សាអំពីតំរូវការ លក្ខណៈបច្ចេកទេស ភាពស្មុគស្មាញ ល័ក្ខខ័ណ្ឌការងារ កត្តាចាំបាច់ ។ល។ របស់មុខសញ្ញាលទ្ធកម្មនីមួយៗ ដែលជាផ្នែកសំខាន់ នៃឯកសារលទ្ធកម្ម ដើម្បីទាក់ទាញ ការប្រកួតប្រជែងអោយបានទូលំទូលាយ ។

-ត្រូវប្រមូលផ្តុំតំរូវការដែលស្ថិតក្នុងប្រភេទដូចគ្នា ហើយមានលក្ខណៈបច្ចេកទេសដូចគ្នា ឬស្រដៀងគ្នា ឬ បំរើអោយការងារតែមួយ ដូចជាប្រភេទ នៃគ្រឿងសង្ហារឹម ឬ សំភារៈការិយាល័យ សំរាប់ " ទំនិញ " ឬ ការងារសាងសង់តូចតាចមួយចំនួនដែលស្ថិតនៅជិតៗ គ្នាជាដើម សំរាប់ "សំណង់" ចាំបាច់ត្រូវបញ្ចូលក្នុងក្រុមតែមួយដែលហៅថា "ឡូត៍លទ្ធកម្ម" ដើម្បីធ្វើកិច្ចលទ្ធកម្មតែមួយលើក ។ ឡូត៍លទ្ធកម្មមួយចំនួន ដែលមានភាពប្រហាក់ប្រហែលគ្នា ឬ ស្រដៀងគ្នាត្រូវបញ្ចូលគ្នា ជាក្រុមធំមួយហៅថា "កញ្ចប់លទ្ធកម្ម" សំរាប់ធ្វើកិច្ចលទ្ធកម្ម តែមួយលើក ។ ការកំណត់ឡូត៍លទ្ធកម្ម និង កញ្ចប់លទ្ធកម្ម ជាទូទៅត្រូវបានប្រើប្រាស់សំរាប់តែទំនិញ និងសំណង់ប៉ុណ្ណោះ ។

ជាទូទៅ ឡូត៍លទ្ធកម្មទាំងអស់ត្រូវប្រមូលផ្តុំជាកញ្ចប់លទ្ធកម្ម ដើម្បីបង្កើនកំរិត និងគុណភាពនៃការប្រកួតប្រជែង ។

វិធានដូចខាងក្រោមត្រូវអនុវត្តនៅពេលប្រមូលផ្តុំទំនិញ ឬ សំណង់អោយទៅជាឡូត៍លទ្ធកម្ម ឬកញ្ចប់លទ្ធកម្មដែលអាចធ្វើកិច្ចលទ្ធកម្មតែមួយលើក :

- ទំនិញ ឬ សំណង់ច្រើនមុខដែលត្រូវធ្វើកិច្ចលទ្ធកម្មតាមវិធីសាស្ត្រតែមួយ ត្រូវធ្វើកិច្ចលទ្ធកម្ម តែមួយលើក ។
- ទំនិញ ឬ សំណង់ច្រើនមុខដែលស្ថិតក្នុងល័ក្ខខ័ណ្ឌកិច្ចសន្យាដូចគ្នា ត្រូវធ្វើកិច្ចលទ្ធកម្ម តែមួយលើក ។
- ទំនិញ ឬ សំណង់ច្រើនមុខដែលត្រូវរៀបចំសំរាប់កិច្ចលទ្ធកម្មក្នុងពេលតែមួយ ត្រូវធ្វើការដេញថ្លៃតែមួយលើក ។
- ទំនិញ ឬ សំណង់ច្រើនមុខដែលមានលក្ខណៈបច្ចេកទេសប្រហាក់ប្រហែលគ្នា ឬ ត្រូវប្រគល់ជូនអ្នកប្រើប្រាស់តែមួយ ត្រូវធ្វើកិច្ចលទ្ធកម្មតែមួយលើក ។

មិនអនុញ្ញាតអោយមានជាដាច់ខាត ចំពោះការបំបែកគំរោង ទៅជាគំរោងតូចៗ ដើម្បីបញ្ចៀសការដេញថ្លៃ ជាសាធារណៈ ។

-ត្រូវផ្អែកលើតំលៃទីផ្សារដើម្បីធ្វើការប៉ាន់ស្មាន តំលៃឯកត្តា តំលៃសរុប និង តំលៃ ក្នុងមួយឡូត៍លទ្ធកម្ម

H

ឬ មួយមុខសញ្ញាលទ្ធកម្ម ឬ មួយកញ្ចប់លទ្ធកម្ម ឬ មួយគំរោងដែលត្រូវធ្វើកិច្ចលទ្ធកម្មមួយលើក។ ។ តំលៃសរុប នៃកិច្ចលទ្ធកម្មទាំងបីប្រភេទ និងបង្ហាញអំពីទឹកប្រាក់ដែលត្រៀមចំណាយសំរាប់ការទូទាត់ប្រចាំឆ្នាំ ។

-ផ្អែកលើតំលៃសរុប និងភាពស្មុគស្មាញរបស់គំរោង ឬ មុខសញ្ញាលទ្ធកម្មនីមួយ។ ត្រូវកំណត់វិធីសាស្ត្រអោយបានសមស្រប ពោលគឺត្រូវបែងចែកអោយបានច្បាស់លាស់ថា គំរោងណាខ្លះត្រូវអនុវត្ត តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែង ជាលក្ខណៈអន្តរជាតិ គំរោងណាខ្លះត្រូវអនុវត្ត តាមវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ហើយប៉ុន្មានគំរោងត្រូវអនុវត្តតាមវិធីសាស្ត្រពិគ្រោះថ្លៃ ឬស្ទង់តំលៃ ទៅតាមកំរិតកំណត់ទឹកប្រាក់ដូចមានក្នុងតារាងជូនភ្ជាប់ ។

-ត្រូវវិភាគ និង កំណត់រយៈពេលគ្រប់ដំណាក់កាលក្នុងដំណើរការលទ្ធកម្មដែលទាក់ទងនឹងគំរោងនីមួយ។ ។ វិធីសាស្ត្រលទ្ធកម្មខុសគ្នា តំរូវអោយប្រើរយៈពេលខុសគ្នា វែង ឬ ខ្លី អាស្រ័យលើកំរិតទឹកប្រាក់ និង ភាពស្មុគស្មាញនៃមុខសញ្ញាលទ្ធកម្ម ។ ចំពោះកិច្ចលទ្ធកម្មដែលមានទឹកប្រាក់ធំ និង មានលក្ខណៈស្មុគស្មាញត្រូវគិតពេលវេលា បន្ថែមសំរាប់ការពិនិត្យ របស់គណៈកម្មាធិការកំណត់បុរេលក្ខណៈសម្បត្តិ វាយតំលៃ និងប្រគល់កិច្ចសន្យា (គបវប)និងការពិនិត្យឡើងវិញរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-ការរៀបចំធ្វើផែនការលទ្ធកម្ម ត្រូវបានបែងចែកជា ដំណាក់កាល ដូចខាងក្រោម :

១-ដំណាក់កាលរៀបចំ :

- ការរៀបចំយថាប្រភេទ និងការប៉ាន់ស្មានតំលៃគំរោង
- ការរៀបចំឯកសារដេញថ្លៃ
- ការអនុម័តលើឯកសារដេញថ្លៃ (ក្រោមសិទ្ធិសំរេច)
- ការផ្តល់ទិដ្ឋាការយល់ព្រមលើឯកសារដេញថ្លៃ ដោយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (ករណីលើសសិទ្ធិសំរេច) ។

២-បុរេលក្ខណៈសម្បត្តិ (ករណីចាំបាច់) :

- ការរៀបចំឯកសារបុរេលក្ខណៈសម្បត្តិ
- ការរៀបចំលិខិតជូនដំណឹង ដើម្បីផ្សព្វផ្សាយ
- ការផ្សព្វផ្សាយ លក់ ទទួល បើកឯកសារបុរេលក្ខណៈសម្បត្តិ
- ការវាយតំលៃជ្រើសរើសក្រុមហ៊ុន ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់

៣-ដំណាក់កាលផ្សព្វផ្សាយ និងបើកឯកសារដេញថ្លៃ :

- ការរៀបចំលិខិតជូនដំណឹង ស្តីអំពីដំណើរការកិច្ចលទ្ធកម្ម
- ការផ្សព្វផ្សាយ (លក់ ទទួល បើកឯកសារដេញថ្លៃ)
- ការចែកកំណត់ហេតុបើកឯកសារដេញថ្លៃ

៤-ដំណាក់កាលវាយតំលៃ :

- ការរៀបចំវាយតំលៃលើសំណើដេញថ្លៃ

Mo

- ការពិនិត្យនិងផ្ដល់អនុសាសន៍របស់ គបវប
- ការពិនិត្យឡើងវិញ និងផ្ដល់អនុសាសន៍ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(ករណីលើសសិទ្ធិសំរេច)

៥-ដំណាក់កាលចុះកិច្ចសន្យា :

- ការធ្វើលិខិតជូនដំណឹងស្ដីពីការសំរេចប្រគល់កិច្ចសន្យា
- ការរៀបចំកិច្ចសន្យា
- ការចុះហត្ថលេខាលើកិច្ចសន្យា

៦-ដំណាក់កាលប្រគល់-ទទួល :

- រយៈពេលប្រគល់-ទទួល (ពេលចាប់ផ្ដើម-ពេលបញ្ចប់)
- ចំនួនលើកដែលត្រូវប្រគល់-ទទួល
- រយៈពេលធានាគុណភាព

៧-ដំណាក់កាលទូទាត់ :

- រយៈពេលទូទាត់ (ពេលចាប់ផ្ដើម-ពេលបញ្ចប់)
- ចំនួនលើកដែលត្រូវទូទាត់

-ដំណាក់កាលនីមួយៗ ខាងលើត្រូវគិតចំនួនថ្ងៃសមស្រប សំរាប់បំពេញក្នុងតារាងផែនការលទ្ធកម្ម ដូចមានគំរូភ្ជាប់ជាមួយ ។

-រយៈពេលធ្វើកិច្ចលទ្ធកម្មគិតពីថ្ងៃចាប់ផ្ដើមរៀបចំឯកសារ រហូតដល់ថ្ងៃចុះហត្ថលេខាលើកិច្ចសន្យាចប់សព្វគ្រប់ ត្រូវបានគិតជាមធ្យមដូចខាងក្រោម :

តារាងកំណត់រយៈពេលមធ្យមសំរាប់ធ្វើកិច្ចលទ្ធកម្ម

ល.រ	មុខសញ្ញាលទ្ធកម្ម	កាលបរិច្ឆេទចាប់ផ្ដើម	កាលបរិច្ឆេទចុះកិច្ចសន្យា	រយៈពេល						ការប្រគល់-ទទួល		ការទូទាត់	
				រយៈពេលសរុប	រៀបចំឯកសារ	បុរេលក្ខណៈសម្បត្តិ	ការផ្សព្វផ្សាយ ដាក់ទទួលពាក្យ និងបើកដោយសាធារណៈ	ការវាយតំលៃ	ការចុះកិច្ចសន្យា	កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់(ខែ)	ចំនួនលើក	កាលបរិច្ឆេទចាប់ផ្ដើម និងបញ្ចប់(ខែ)	ការបែងចែកចំនួនលើកនីមួយៗ
				ចំនួនថ្ងៃ	ចំនួនថ្ងៃ	ចំនួនថ្ងៃ	ចំនួនថ្ងៃ	ចំនួនថ្ងៃ	ចំនួនថ្ងៃ				
	១	២	៣	៤	៥	៦	៧	៨	៩	១០	១១	១២	១៣
1	ដបអ			120	20	-	50	30	20				
2	ដបស			50	10	-	20	10	10				
3	ពថ			40	8	-	15	10	7				
4	សត			17	5	-	-	7	5				

កំណត់សំគាល់ : ដបអ :ដេញថ្លៃដោយប្រកួតប្រជែងជាអន្តរជាតិ ដបស : ដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក ពថ : ពិគ្រោះថ្លៃ សត : ស្ទង់តំលៃ

-ចំពោះកិច្ចលទ្ធកម្ម ដែលត្រូវធ្វើបុរេលក្ខណៈសម្បត្តិ រយៈពេលសរុបត្រូវបូកបន្ថែមរយៈពេលធ្វើបុរេលក្ខណៈសម្បត្តិ ។ រយៈពេលសំរាប់ធ្វើបុរេលក្ខណៈសម្បត្តិត្រូវបានគិតជាមធ្យម ៤០ថ្ងៃ ។

-រយៈពេលប្រគល់-ទទួល និងទូទាត់អាស្រ័យលើស្ថាប័នអនុវត្តលទ្ធកម្ម ពិនិត្យជាក់ស្ដែង ដោយផ្អែកលើ

ប្រភេទនៃកិច្ចលទ្ធកម្មនីមួយៗ ។

-ការកសាងផែនការលទ្ធកម្មចាំបាច់ត្រូវមានការ ចូលរួមយ៉ាងសកម្ម ពីអង្គភាពពាក់ព័ន្ធ ក្នុងការផ្តល់ទិន្នន័យ ដូចជា បរិមាណ តំលៃ លក្ខណៈបច្ចេកទេស ។ល។ ដល់អង្គភាពលទ្ធកម្មអោយបានទាន់ពេលវេលា ។

-ចំពោះកិច្ចលទ្ធកម្មដែលត្រូវអនុវត្តតាមវិធីសាស្ត្រលទ្ធកម្មដោយឡែក ស្ថាប័នអនុវត្តលទ្ធកម្មត្រូវធ្វើគំរោង ដើម្បីសុំការសំរេចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមការជាក់ស្តែង ។

-រាល់ការប្រគល់-ទទួល និងការទូទាត់ចាំបាច់ត្រូវធ្វើអោយបានរួចរាល់ ក្នុងឆ្នាំសារពើពន្ធនីមួយៗ។ ក្នុងករណី មានបន្តការប្រគល់-ទទួលឆ្លងឆ្នាំ ឬ ទូទាត់មិនទាន់នោះ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ មិនទទួលខុសត្រូវ ក្នុងការធ្វើអាណត្តិដឹកលុយជូនឡើយ ហើយសាមីស្ថាប័ន អនុវត្តលទ្ធកម្ម ត្រូវប្រើប្រាស់កញ្ចប់ថវិកាឆ្នាំបន្ទាប់ របស់ខ្លួន ដើម្បីដំណើរការទូទាត់ ។

-កិច្ចសន្យាទាំងឡាយណា ដែលគ្មានក្នុងផែនការលទ្ធកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នឹងមិនទទួលខុសត្រូវ ក្នុងការទូទាត់ជូនឡើយ ហើយសាមីស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវទទួលខុសត្រូវ លើរាល់បាតុភាពអសកម្ម ដែល នឹងកើតឡើងជាយថាហេតុ ។

ទទួលបានសារាចរណែនាំនេះ សូមព្រះអង្គម្ចាស់ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង គ្រប់រដ្ឋលេខាធិការដ្ឋាន អភិបាលគ្រប់ខេត្ត-ក្រុង ប្រធានសហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាល យកចិត្តទុកដាក់ អនុវត្តអោយបានម៉ឺងម៉ាត់ និងមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/៚

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

<u>កន្លែងទទួល</u>

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-គ្រប់ក្រសួង-ស្ថាប័ន
-គ្រប់ខេត្ត-ក្រុង
-គ្រប់សហគ្រាសសាធារណៈ,គ្រឹះស្ថានសាធារណៈលក្ខណៈរដ្ឋបាល
-គ្រប់នាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៩៧៧ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " ថ្លាធ្លង់ "

ស្ថិតនៅក្នុង ឃុំ ថ្លាធ្លង់ ស្រុក រំដួល ខេត្ត ស្វាយរៀង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើតសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ថ្លាធ្លង់ ស្រុក រំដួល ចុះថ្ងៃទី ០៣ កក្កដា ២០០៦ ដោយមានយោបល់ ឯកភាពពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ស្វាយរៀង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " ថ្លាធ្លង់ " ស្ថិតនៅក្នុង ឃុំ ថ្លាធ្លង់ ស្រុក រំដួល ខេត្ត ស្វាយរៀង ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ស្វាយរៀង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៦

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" ដើម្បីជ្រាបជាពត៌មាន "
-សាលា ខេត្ត ស្វាយរៀង "ដើម្បីជាពត៌មាន"
-ដូចប្រការ៤
-កាលប្បវត្តិ-ឯកសារ នា មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៩៧៣ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " អង្គតាសូរ "

ស្ថិតនៅក្នុង ឃុំ អង្គតាសូរ ស្រុក ស្វាយជ្រំ ខេត្ត ស្វាយរៀង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ អង្គតាសូរ ស្រុក ស្វាយជ្រំ ចុះថ្ងៃទី ១៥ កក្កដា ២០០៦ ដោយមានយោបល់ ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ស្វាយរៀង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **អង្គតាសូរ** " ស្ថិតនៅក្នុង ឃុំ អង្គតាសូរ ស្រុក ស្វាយជ្រំ ខេត្ត ស្វាយរៀង ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ស្វាយរៀង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ២០០៦

បណ្ឌិត គឹុណ ណេង

កន្លែងទទួល:

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- -សាលា ខេត្ត ស្វាយរៀង "ដើម្បីជាពត៌មាន"
- -ដូចប្រការ៤
- -កាលប្បវត្តិ-ឯកសារ នា.មចទ

Ith Chetha NewSchool.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខៈ ១៩៧៤ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " អណ្តូងពោធិ៍ "

ស្ថិតនៅក្នុង ឃុំ អណ្តូងពោធិ៍ ស្រុក រមាសហែក ខេត្ត ស្វាយរៀង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ អណ្តូងពោធិ៍ ស្រុក រមាសហែក ចុះថ្ងៃទី ១០ សីហា ២០០៦ ដោយមានយោបល់ ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ស្វាយរៀង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **អណ្តូងពោធិ៍** " ស្ថិតនៅក្នុង ឃុំ អណ្តូងពោធិ៍ ស្រុក រមាសហែក ខេត្ត ស្វាយរៀង ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ស្វាយរៀង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ ៩ ឆ្នាំ២០០៦

ហត្ថលេខា ក៏ម សេង

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលា ខេត្ត ស្វាយរៀង "ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ ទា.មចទ

Ite Chetha NewSchool.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៩៦៤ អយក.ប្រក

ប្រកាស

ស្តីពីការបើកអនុវិទ្យាល័យ " **ស្វាយធន្ទឹម** "

ស្ថិតនៅក្នុង ឃុំ ត្រពាំងស្តៅ ស្រុក រមាសហែក ខេត្ត ស្វាយរៀង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ ត្រពាំងស្តៅ ស្រុក រមាសហែក ចុះថ្ងៃទី ០៩ សីហា ២០០៦ ដោយមានយោបល់ ឯកភាពពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត ស្វាយរៀង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **ស្វាយធន្ទឹម** " ស្ថិតនៅក្នុង ឃុំ ត្រពាំងស្តៅ ស្រុក រមាសហែក ខេត្ត ស្វាយរៀង ចាប់ពីឆ្នាំសិក្សា ២០០៦-២០០៧ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត ស្វាយរៀង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០០៦

បណ្ឌិត **កុល ពេង**

កន្លែងទទួល:

-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
" ដើម្បីជ្រាបជាពត៌មាន "
-សាលា ខេត្ត ស្វាយរៀង "ដើម្បីជាពត៌មាន"
-ដូចប្រការ៤
-កាលប្បវត្តិ-ឯកសារ ទា.មចទ

hh Chetha/New School.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១៥៦៦ អយក.ប្រក

ប្រ ក ា ស

ស្តីពីការបើកអនុវិទ្យាល័យ " **សំបូរ** "

ស្ថិតនៅក្នុង ឃុំ សំបូរ ស្រុក ស្វាយទាប ខេត្ត ស្វាយរៀង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
